**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.ទីន លក្ខិណា**

**ទីន បញ្ញា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឈុន ណារ៉ែត**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្រ្តាចារ្យណែនាំ |
| និស្សិតឈ្មោះ **ក.ទីន លក្ខិណា** | **បណ្ឌិត ឈុន ណារ៉េត** |
| **ទីន បញ្ញា** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលសិក្សា ២០១៧ |
| ជំនាន់ទី ១៤ | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម យើងខ្ញុំឈ្មោះ **ទីន លក្ខិណា** និង **ទីន បញ្ញា** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែក រដ្ឋបាលសាធារណៈ ឆ្នាំទី៤ ឆមាសទី២ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្ដែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោក**ឪពុក** និង**អ្នកម្ដាយ**ដែលបាន ផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំណែនាំ និងការឧបត្ថម្ភគ្រប់បែបយ៉ាងទាំងធនធាន (ថវិកា និងសម្ភារៈ) និងស្មារតីដល់ខ្ញុំគ្រប់បែបយ៉ាងរហូតដល់កូនមានឱកាសបានសិក្សារៀនសូត្រដល់ថ្ងៃ បញ្ចប់ថ្នាក់មហាវិទ្យាល័យ ដោយលោកទាំងពីរខិតខំ ជំនះរាល់ឧបសគ្គ មិនខ្លាចនឿយហត់ ពុះពារឱ្យកូនបានរៀនសូត្រ មានចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីរួមរស់នៅក្នុងសង្គមប្រកបដោយសុភវិនិច្ឆ័យ។ ហើយយើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ បណ្ឌិតទាំងអស់ដែលបានខិតខំផ្ទេរចំណេះដឹង និងការស្វាគមន៍ដ៏រាក់ទាក់ កក់ក្ដៅបំផុតក្នុងការជួយសម្រួលផ្នែកឯកសារ ទិន្នន័យ ស្មារតី និងសម្ភារៈផ្សេងៗ ដើម្បីបានផ្ដល់លទ្ធភាពដល់យើងខ្ញុំក្នុងការបន្តការសិក្សា និងឈានដល់ការសរសេរសារណាប្រកបដោយជោគជ័យពីសំណាក់៖

- **លោកឪពុក ទីន សាំ និង អ្នកម្ដាយ ម៉ោល សារ៉ន** ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ផ្ដល់ដំបូន្មាន និងជួយឧបត្ថម្ភគាំទ្រទាំងកម្លាំងកាយចិត្ត និងជួយសម្របសម្រួលដំណើរការសរសេរសារណាគ្រប់បែបយ៉ាង
- **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រងទាំងអស់ដែលបានខិតខំដឹកនាំសាកលវិទ្យាល័យ និងសម្របសម្រួលរាល់តម្រូវការនៃការសិក្សារបស់និស្សិត
- លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន អប់រំ ណែនាំ ផ្ដល់មតិយោបល់ ផ្ដល់ឯកសារ និងត្រួតពិនិត្យសារណាស្រាវជ្រាវនេះយ៉ាងយកចិត្តទុកដាក់ និងទឹកចិត្តរីករាយ
- មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់គ្នា ដែលបានជំរុញលើកទឹកចិត្ត ផ្ដល់ព័ត៌មាន ពិភាក្សាផ្លាស់ប្ដូរយោបល់ ចំណេះដឹង រួមទាំងបទពិសោធន៍ល្អៗ ក្នុងការស្វែងរកដំណោះស្រាយក្នុងការស្រាវជ្រាវ យើងខ្ញុំសូមថ្លែងអំណរគុណ ជូនពរដល់លោកអ្នកទាំងអស់គ្នា សូមជួបតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ ស្ដីពី **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ** គឺជាស្នាដៃ និងជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងក្នុងសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ ដោយបានស្វែងរកឯកសារពីគ្រប់មជ្ឈដ្ឋាន ដើម្បីគាំទ្រប្រធានបទ។ សារណានេះបានឆ្លុះបញ្ចាំង នូវសមត្ថភាពដែលខ្ញុំមាន និងទទួលបានពីការសិក្សាស្រាវជ្រាវពីឯកសារនានាដែលពាក់ព័ន្ធ ដើម្បីមកធ្វើការបកស្រាយនូវប្រធានបទមួយនេះឱ្យបានល្អ។

ប្រធានបទដែលយើងខ្ញុំទាំងពីរនាក់ឈ្មោះ **ទីន លក្ខិណា** និង **ទីន បញ្ញា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៤ ក្នុងឆ្នាំសិក្សា២០២០-២០២១ បានសម្រេចចិត្តជ្រើសរើសមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ គឺជាប្រធានបទដែលកើតចេញពី ការសង្កេតឃើញជាក់ស្ដែង និង ឆន្ទៈ ចង់សិក្សាស្រាវជ្រាវ ព្រមទាំងមានការជម្រុញពីសាស្ត្រាចារ្យ និងមិត្តរួមថ្នាក់ផងដែរ។ ម្យ៉ាងទៀតដោយសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាកំពុងតែយកចិត្តទុកយ៉ាងខ្លាំង ទៅលើការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់នេះ ។ ជាពិសេស ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់អាណត្តិទី៥ ក៏ជិតមកដល់ទៀត គឺនៅឆ្នាំ២០២២ ខាងមុខនេះ។ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានផ្ដល់ឱកាសជាច្រើនដល់រាជរដ្ឋាភិបាល ក្នុងកិច្ចបន្តកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់។ ជាក់ស្ដែង ក្របខណ្ឌយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ និងអភិបាលកិច្ចល្អ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបង្កើតក្នុងឆ្នាំ២០០១ ដូចគ្នា ដែលសំដៅឱ្យដំណើរការរដ្ឋបាល ឃុំ សង្កាត់កាន់តែល្អប្រសើរ។ ក្រៅពីនេះកម្មវិធីជាតិ និងកម្មវិធីនយោបាយនានារបស់រាជរដ្ឋាភិបាលក៏បានត្រួសត្រាយផ្លូវបន្ថែមបម្រើឱ្យការងារ ការគ្រប់គ្រងនេះបានសម្រេចដោយភាពជោគជ័យ។ ដោយមើលឃើញដូចនេះ ទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទនេះមកសរសេរជាសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ សារណាមួយនេះ ត្រូវបានបញ្ចប់ដោយជោគជ័យ តែមិនមែនមានន័យថាមិនមានកំហុសឆ្គងកើតឡើងនោះឡើយ។ ភាពខុសឆ្គងដែលកើតមានឡើងក្នុងសារណានេះគឺដោយសារតែចំណេះដឹងនូវមានកម្រិត ហើយមួយវិញទៀត ការរីករាលដាលនៃជំងឺដ៏កាចសាហាវដែលពិបាកក្នុងការធ្វើចរាចរ ដើម្បីស្វែងរក ទិន្នន័យ ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធ ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលអាចនឹងកើតមានឡើងដោយប្រការណាមួយពីសំណាក់ លោកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ហើយយើងខ្ញុំក៏រីករាយនឹងទទួលយកនូវការរិះគន់ដើម្បីជាទុនក្នុងការស្ថាបនា និងការកែលម្អ ដើម្បីឱ្យកាន់តែមានភាពល្អប្រសើរក្នុងការសិក្សាស្រាវជ្រាវនៅលើកក្រោយទៀត។

# មាតិកា

**ទំព័រ**

**បញ្ជីអក្សរកាត់** ........ iv

**បញ្ជីរូបភាព** ........ v


## សេចក្តីផ្តើម

១ លំនាំបញ្ហានៃការស្រាវជ្រាវ........ ១

២ ចំណោទបញ្ហានៃការស្រាវជ្រាវ........ ២

៣ គោលបំណងនៃការស្រាវជ្រាវ........ ២

៤ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦ វិធីសាស្រ្តស្រាវជ្រាវ ........ ៣

៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១

## លក្ខណៈទូទៅនៃវិមជ្ឈការ

១.១ អត្ថន័យនៃវិមជ្ឈការ ........ ៥

១.១.១ និយមន័យ........ ៥

១.១.២ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ ........ ៥

១.២ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់តាមបែបវិមជ្ឈការ........ ៦

១.៣ ទិសដៅវិមជ្ឈការ........ ៧

១.៤ ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការ ឃុំ សង្កាត់ ........ ៧

១.៥ តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់ ........ ១០

១.៥.១ អំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ........ ១០

១.៥.២ តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់........ ១១

១.៦ ព្រំដែននៃអំណាច ........ ១១

១.៧ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់........ ១២

១.៨ ទំនាក់ទំនងអន្តររដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់........ ១៤

១.៨.១ ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ........ ១៤

១.៨.២ ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ..... ១៤
១.៨.៣ ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងាររបស់រដ្ឋ ......... ១៥
១.៩ ការតាមដាន ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍ ............ ១៥

## ជំពូកទី ២

## ដំណើរការនៃការគ្រប់គ្រងកិច្ចការរដ្ឋបាលឃុំ សង្កាត់

២.១ លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ............ ១៧
២.១.១ និយមន័យលិខិតបទដ្ឋានគតិយុត្ត ............ ១៧
២.១.២ ប្រភេទលិខិតបទដ្ឋានគតិយុត្ត ............ ១៧
២.២. លិខិតរដ្ឋបាលឃុំ សង្កាត់ ............ ១៨
២.២.១ និយមន័យលិខិតរដ្ឋបាល ............ ១៨
២.២.២ ប្រភេទលិខិតរដ្ឋបាល ............ ១៨
២.៣ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ............ ១៩
២.៣.១ អំពីការរៀបចំបទបញ្ជាផ្ទៃក្នុង ............ ១៩
២.៣.២. ការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ............ ២០
២.៣.៣ ការពិនិត្យនីត្យានុកូលភាពនៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ............ ២០
២.៤ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ............ ២១
២.៤.១ ចំណូលផ្ទាល់ ............ ២១
២.៤.២ ចំណូលពីមូលនិធិឃុំ សង្កាត់ ............ ២១
២.៤.៣ ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ ............ ២២
២.៥ របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់ ............ ២២
២.៦ កិច្ចលទ្ធកម្មឃុំ សង្កាត់ ............ ២២
២.៦.១ គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្ម ............ ២២
២.៦.២ សមាសភាពគណៈកម្មការលទ្ធកម្ម ............ ២៣
២.៦.៣ វិធីសាស្ត្រលទ្ធកម្ម ............ ២៣
២.៦.៤ ការទូទាត់ ............ ២៣
២.៧ ប្រព័ន្ធកសាងផែនការឃុំ សង្កាត់ ............ ២៣
២.៨ តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ ............ ២៥
២.៨.១ ក្រុមប្រឹក្សាឃុំ សង្កាត់ ............ ២៥

២.៨.២ មេឃុំ ចៅសង្កាត់ ............ ២៥
២.៨.៣ គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់(គ.ផ.ថ) ............ ២៥
២.៨.៤ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក) ............ ២៥
២.៨.៥ មន្ទីរផែនការរាជធានី ខេត្ត ............ ២៦
២.៨.៦ ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ............ ២៦
២.៨.៧ ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ឬការិយាល័យផែនការ និងអភិវឌ្ឍន៍ ............ ២៧
២.៨.៨ ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ ............ ២៧
២.៨.៩ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានាថ្នាក់រាជធានី ខេត្ត ............ ២៧
២.៨.១០ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ............ ២៧
២.៨.១១ ប្រជាពលរដ្ឋ ............ ២៨
២.៩ ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ............ ២៨
២.១០ ដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ............ ៣២
២.១១ ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ ............ ៣៥
២.១១.១ និយមន័យភូមិ ............ ៣៥
២.១១.២ បែបបទ និងនីតិវិធីនៃការជ្រើសរើសមេភូមិ ............ ៣៦
២.១២ ការតែងតាំងជំនួយការមេភូមិ ............ ៤២

## ជំពូកទី៣

## គុណសម្បត្តិ និង គុណវិបត្តិ

៣.១ គុណសម្បត្តិ ............ ៤៥
៣.២ គុណវិបត្តិ ............ ៤៩
**សេចក្តីសន្និដ្ឋាន** ............ ៥១
**អនុសាសន៍** ............ ៥៣
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

ស.ណ.ន ៖ សេចក្តីណែនាំ

គ.ផ.ថ ៖ គណៈកម្មធិការកសាងផែនការ និងថវិកាឃុំ សង្កាត់

គ.ក.ន.ក ៖ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

# បញ្ជីរូបភាព

រូបភាពទី១ ៖ រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ ........................................................................ ១៣

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងបណ្ដាប្រទេសប្រើប្រាស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យត្រូវបានប្រទេសជាតិមួយចំនួនធំក្នុងពិភពលោកបានទទួលស្គាល់ថាវាជាកត្តាមួយដែលជំរុញអោយប្រទេសជាតិមានការរីកចម្រើនប្រកបដោយចីរភាព។ ដោយហេតុថា ការគ្រប់គ្រងប្រភេទនេះបានផ្ដល់ឱកាសដល់ប្រជារាស្ត្រគ្រប់រូបចូលរួមកសាងប្រទេសជាតិរួបរួមគ្នា និងការការពារនូវផលប្រយោជន៍រួមដែលស្ដែងចេញតាមរយៈ ការបោះឆ្នោតជ្រើសរើសអ្នកតំណាងដើម្បីការពារផលប្រយោជន៍របស់ពួកគេ។ បែបនេះហើយទើបបច្ចុប្បន្នគេអាចសម្គាល់ប្រទេសមួយថាជាប្រទេសដែលប្រកាន់របបប្រជាធិបតេយ្យដោយសារតែ នៅក្នុងប្រទេសមួយនោះមានការបោះឆ្នោតជ្រើសរើសអ្នកកាន់កាប់អំណាចដើម្បីបម្រើផលប្រយោជន៍រួម។ ជាក់ស្ដែង វត្តមានលទ្ធិប្រជាធិបតេយ្យមានរយៈពេលជាយូរលង់ណាស់មកហើយ បើយើងគិតចាប់ពីពេលដែល មនុស្សជាតិចាប់ផ្ដើមរស់នៅជាមួយគ្នាជាកុលសម្ព័ន្ធដែលក្នុងនោះធ្វើការជ្រើសរើសក្នុងចំណោមញាតិព័ន្ធរបស់ខ្លួន។ ដោយមើលឃើញថាការវិវត្តរបបនយោបាយនៅប្រទេសនីមួយៗមានភាពខុសគ្នាហើយរយៈពេលក៏ខុសៗគ្នាទៅតាមបរិបទក្នុងសង្គមរបស់ប្រទេសទាំងនោះ។ ដោយខ្លះនៅតែរក្សាការគ្រប់គ្រងប្រទេសរបស់ពួកគេតាមបែបសង្គមនិយមខ្លះទៀត ក៏វិវត្តន៍មកជារបបសេរីនិយម ឬតាមបែបលទ្ធិប្រជាធិបតេយ្យ។ ការគ្រប់គ្រងតាមបែបលទ្ធិប្រជាធិបតេយ្យនេះទៀតសោតមានច្រើនរបៀបច្រើនទម្រង់ទៅតាមប្រភេទនៃរដ្ឋនីមួយៗ (រដ្ឋទោល រឺ រដ្ឋសហព័ន្ធ)។

ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាយើង បានឆ្លងកាត់របបគ្រប់គ្រងជាច្រើនដោយគ្រាន់តែរាប់បញ្ចូលរបបគ្រប់គ្រងមុនសម័យអាណានិគមបារាំងយើងក៏បានឃើញថា ការគ្រប់គ្រងប្រទេសកម្ពុជាមានការប្រែប្រួល និងវិវត្តជាច្រើនលើកមកហើយពី ការគ្រប់គ្រងតាមបែបរាជានិយមផ្ដាច់ការរហូតមកដល់មានការបោះឆ្នោត និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ ដោយយោងទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា [1] ប្រទេសកម្ពុជាប្រកាន់ខ្ជាប់នូវ របបរាជាធិបតេយ្យអាស្រ័យពហុបក្សហើយប្រជាពលរដ្ឋប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈរដ្ឋសភាព្រឹទ្ធសភារដ្ឋាភិបាល និងតុលាការ។ ដូចនេះហើយអំណាចនៃការគ្រប់គ្រងជាតិគឺមិនប្រមូលផ្ដុំតែបុគ្គលតែម្នាក់ ឬស្ថាប័នណាមួយឡើយអំណាចត្រូវបានបែងចែកជាបីគឺអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)

មិនតែប៉ុណ្ណោះ កម្ពុជាក៏បានកំពុងនឹងព្យាយាមក្នុងការធ្វើកំណែទម្រង់អភិវឌ្ឍន៍រដ្ឋបាលរបស់ខ្លួនយ៉ាងស្វិតស្វាញផងដែរ។ ដំណាក់ការនៃការវិវត្តរដ្ឋបាលកម្ពុជាត្រូវបានបែងចែកចេញជា ៣ ដំណាក់កាលគឺ ៖ ដំណាក់កាលនៃការកសាងមូលដ្ឋានគ្រឹះ (១៥ឆ្នាំ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ ២០០៨) ដំណាក់កាលនៃការអភិវឌ្ឍ (១៥ឆ្នាំ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ ២០០៨) ដំណាក់ការនៃការពង្រឹងប្រសិទ្ធភាព(ពីឆ្នាំ២០០៨ដល់ បច្ចុប្បន្ននេះ)[2] ។ កម្ពុជាបានរៀបចំរដ្ឋបាលឱ្យមានភាពប្រសើរឡើងដោយបង្កើតឱ្យមានការបែងចែកអំណាច និងការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិមករដ្ឋបាលថ្នាក់ក្រោមជាតិតាមបែប( វិមជ្ឈការ និង វិសហមជ្ឈការ )។

## ២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះស្តីអំពី **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ** បានបង្ហាញអោយឃើញនូវបញ្ហាចោទដូចខាងក្រោម ៖

- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ប្រព្រឹត្តទៅ និងអនុវត្តយ៉ាងដូចម្តេច?
- តើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការអាចឱ្យប្រជាពលរដ្ឋនៅក្នុងសហភាពមូលដ្ឋានទទួលបាននូវអត្ថប្រយោជន៍អ្វីខ្លះ?
- តើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការផ្តល់នូវគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះ?

## ៣ គោលបំណងនៃការស្រាវជ្រាវ

មូលហេតុដែលក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ គឺ ក្នុងគោលបំណងរកឱ្យឃើញថា ការបំពេញតួនាទីរបស់មន្ត្រីក្នុងមូលដ្ឋានមានការអនុវត្ត និងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននោះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌ដែរឬទេ? ហើយការសិក្សាស្រាវជ្រាវនេះដើម្បីធ្វើការវាយតម្លៃអំពី ៖

- ការបំពេញតួនាទី ភារកិច្ច និងការគ្រប់គ្រងនៅក្នុងឃុំ សង្កាត់
- កំណត់អំពីសមត្ថភាពរបស់មន្ត្រីទៅលើការអនុវត្តការងារ
- វាយតម្លៃអំពីសមិទ្ធផលដែលសម្រេចបាន

របកគំហើញនៃការស្រាវជ្រាវនៃប្រធានបទមួយនេះ គឺដើម្បីធ្វើការកែលម្អ បំពេញបន្ថែមនូវចំណុចដែលមានភាពខ្វះខាត នៅថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ ចំណុចដែលប៉ះពាល់ដល់ការងារ និងប្រជាពលរដ្ឋ ព្រោះបើ

[2] សួង លាងហៃ (២០១០).ការវិវត្តនៃរដ្ឋបាលកម្ពុជា(១៩៩៣-២០០៨) [និក្ខេបបទបណ្ឌិតជាសាស្ត្រនយោបាយ]មហាវិទ្យាល័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ].

ការគ្រប់គ្រង និងបំពេញតួនាទីរបស់មន្ត្រីនៅថ្នាក់មូលដ្ឋានមានភាពខ្វះខាត មិនបានគ្រប់ជ្រុងជ្រោយមិនមានភាពអំណោយផលអាចនឹងជះឥទ្ធិពលដល់ការអភិវឌ្ឍ សេដ្ឋកិច្ចជាតិទាំងមូល។

## ៤ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺសំដៅទៅលើការគ្រប់គ្រងឃុំ សង្កាត់ដោយវិធីណាទើបប្រកបដោយប្រសិទ្ធិភាព តម្លាភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដើម្បីមានការអភិវឌ្ឍនៅតាមឃុំ សង្កាត់របស់ខ្លួន។ ហេតុផលដែលរាជរដ្ឋាភិបាលធ្វើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការនេះឡើង និងសមិទ្ធផលដែលការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទទួលបាននៅក្នុងឆ្នាំ២០០២ មកទល់បច្ចុប្បន្ននេះដោយផ្អែកទៅលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១ ។

## ៥ សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់ដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះវាអាចជាចំណេះដឹង និងគោលការណ៍ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ហើយវាក៏ជាឯកសារសំខាន់សម្រាប់ឱ្យនិស្សិត អ្នកសិក្សាស្រាវជ្រាវ ប្រជាពលរដ្ឋ និងមន្ត្រីរាជការទាំងអស់បានឈ្វេងយល់ និងបំពេញបន្ថែមនូវចំណុចខ្វះខាត និងធ្វើយ៉ាងណាដើម្បីធានានូវការគ្រប់គ្រង និងអនុវត្តប្រកបទៅដោយប្រសិទ្ធិភាព និងអភិបាលកិច្ចល្អ នៅក្នុងថ្នាក់ឃុំ សង្កាត់ដែលជាកត្តានាំឱ្យមានការអភិវឌ្ឍដល់សង្គម។

## ៦ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីធ្វើការប្រមូលព័ត៌មាន និងឯកសារយកមកចងក្រងជាឯកសារណាមួយនេះឱ្យបានល្អ គឺមានការធ្វើសកម្មភាពស្រាវជ្រាវតាមវិធីសាស្ត្រជាច្រើនដូចជា ៖

- បណ្ណាល័យ
- ដកស្រង់ចេញពីសៀវភៅដែលពាក់ព័ន្ធនឹងប្រធានបទ
- ចំណេះដឹងដែលសិក្សាកន្លងមក
- ដកស្រង់ចេញពីប្រសាសន៍របស់សាស្ត្រាចារ្យណែនាំផ្ទាល់
- ទិន្នន័យចម្បង ៖ សៀវភៅ **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ** របស់ក្រសួងមហាផ្ទៃ បោះពុម្ព ខែកក្កដា ឆ្នាំ២០១៧
- ទិន្នន័យបន្ទាប់បន្សំ ៖ ក្រៅពីមានការប្រមូលបាននូវអនុក្រឹតខាងលើយើងខ្ញុំក៏បានស្រាវជ្រាវបន្ថែមទៀតចេញពីសៀវភៅ **នីតិរដ្ឋបាលទូទៅ បណ្ឌិត សាយ បូរី** បោះពុម្ពលើកទី៤ ទំព័រ ៣៩៣-៤០១។

ក្រោយពីក្រុមយើងខ្ញុំបានប្រមូលនូវប្រភពទិន្នន័យដ៏សំខាន់ៗខាងលើនេះរួចមកក្រុមយើងខ្ញុំក៏បានប្រើប្រាស់នូវការវិភាគទិន្នន័យបែបពិព៌ណ៌នាដោយផ្អែកលើទិន្នន័យដែលមានស្រាប់ខាងលើនេះដើម្បីយកមកសរសេររៀបចំឡើងដើម្បីឱ្យមានភាពជឿជាក់ និងទទួលយកបាន។

## ៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**មាតិកា**

**សេចក្តីផ្តើម**

**ជំពូកទី១ ៖** ជំពូកនេះបង្ហាញអំពី និយមន័យ ទិដ្ឋភាពសំខាន់ៗ នៅក្នុងវិមជ្ឈការ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់តាមបែបវិមជ្ឈការ ទិសដៅវិមជ្ឈការ ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការ ឃុំ សង្កាត់រចនាសម្ព័ន្ធនៃរដ្ឋបាល ឃុំ សង្កាត់ទំនាក់ទំនងអន្តររដ្ឋបាលរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ការតាមដាន ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍

**ជំពូកទី២ ៖** ជំពូកនេះបង្ហាញអំពី ដំណើរការនៃការគ្រប់គ្រងកិច្ចការរដ្ឋបាលឃុំ សង្កាត់ កិច្ចការរដ្ឋបាលឃុំ សង្កាត់លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ការគ្រប់គ្រងឯកសារឃុំ សង្កាត់ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រភពចំណូល របាយការណ៍ហិរញ្ញវត្ថុលទ្ធកម្មឃុំ សង្កាត់ ប្រព័ន្ធកសាងផែនការឃុំ សង្កាត់គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគឃុំ សង្កាត់ តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ ដំណើរការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ និយមន័យមេភូមិ បែបបទ និតិវិធីនៃការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ អាណត្តិការងាររបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ។

**ជំពូកទី៣ ៖** ជំពូកនេះនិយាយអំពី គុណសម្បត្តិ និងគុណវិបត្តិ

**សេចក្តីសន្និដ្ឋាន ៖** តាមរយៈការស្រាវជ្រាវនូវប្រធានបទខាងលើនេះ យើងខ្ញុំយល់ឃើញថារដ្ឋាភិបាលបានខិតខំកែប្រែ និងអនុវត្តនូវគោលនយោបាយក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការគឺដើម្បីសម្រួលអោយមានភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន អោយកាន់តែមានភាពរហ័ស និងងាយស្រួលជាងមុន ជាពិសេសកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋកាន់តែតិច និងចំណេញពេលវេលា។ ម៉្យាងវិញទៀត ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនេះ បានចូលរួមក្នុងការផ្តល់អំណាចដល់រាស្ត្រក្នុងការជ្រើសរើសអ្នកតំណាងតាមរយៈការបោះឆ្នោតជ្រើសរើសដំណាងរាស្ត្រដែលពួកគេស្រលាញ់ ។

**អនុសាសន៍**

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# ជំពូកទី១
# លក្ខណៈទូទៅនៃវិមជ្ឈការ

# ជំពូកទី១

# លក្ខណៈទូទៅនៃវិមជ្ឈការ

## ១.១ អត្ថន័យនៃវិមជ្ឈការ

### ១.១.១ និយមន័យ

វិមជ្ឈការ មានន័យថា រាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និង ធនធាន ដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ លើបញ្ហាទាំងនេះ[3] ។

វិមជ្ឈការឃុំ សង្កាត់មានន័យថា សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធានមួយចំនួនត្រូវបានផ្ទេរពី រដ្ឋបាលថ្នាក់ជាតិទៅឱ្យក្រុមប្រឹក្សា ឃុំ សង្កាត់ដែលបានបោះឆ្នោតជ្រើសរើសដោយ ប្រជាពលរដ្ឋតាមលក្ខណៈ ប្រជាធិបតេយ្យ។

### ១.១.២ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ

ប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់របស់ ខ្លួន។ ហើយប្រជាពលរដ្ឋត្រូវបានផ្ដល់សិទ្ធិ និងការទទួលខុសត្រូវឱ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍ មូលដ្ឋាន ឃុំ សង្កាត់របស់ខ្លួន។ លើសពីនេះទៅទៀត ក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់ត្រូវបានបោះឆ្នោតជ្រើស រើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ។ ដូច្នេះ ក្រុមប្រឹក្សានេះជាតំណាងឱ្យប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់ របស់ខ្លួន។

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវបានផុតកំណត់ទៅវិញនៅពេលដែលមានក្រុមប្រឹក្សា ឃុំ សង្កាត់ថ្មីចូលកាន់តំណែង។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ដល់ការទទួលខុសត្រូវ និងភារកិច្ចជាច្រើន ដែលខុសប្លែកទាំងស្រុងពីការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់កាលពីមុនបោះឆ្នោត ឆ្នាំ ២០០២។ ជាពិសេស ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់គឺអភិវឌ្ឍន៍ ឃុំ សង្កាត់ហើយលើក កម្ពស់សុខុមាលភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនថែមទៀតផង។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឱ្យបានថាសហគមន៍នៅមូលដ្ឋានចូលរួមយ៉ាងពេញលេញ និងសកម្ម នៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និងសេចក្ដីសម្រេចនានាដែលមានឥទ្ធិពលទៅ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជា សេចក្ដីសម្រេចលើការប្រើប្រាស់ធនធានសម្រាប់ការអភិវឌ្ឍមូលដ្ឋាន

[3] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ ទំព័រ១

របស់ខ្លួនជាដើម។ ការធ្វើសេចក្ដីសម្រេចដែលមានការចូលរួមពីប្រជាពលរដ្ឋទើបសេចក្ដីសម្រេចនោះទទួលបាននូវប្រសិទ្ធភាពខ្ពស់។

ជាការពិតណាស់អ្វីក៏ដោយបើគ្មានការចូលរួមពីប្រជារាស្ត្រនោះទេ ទោះបីរដ្ឋខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយក៏វាមិនអាចទៅរួចដែរដូចជាការងារអភិវឌ្ឍន៍នានាជាដើម។ ឃើញស្រាប់ហើយបើរាស្ត្រគ្មានលទ្ធភាពនិងចូលរួមនោះទេការអភិវឌ្ឍពិតប្រាកដវាបានត្រឹមតែអភិវឌ្ឍន៍ខ្លួនឯងប៉ុណ្ណោះ។ ឧទាហរណ៍៖ ក្រុមមន្ត្រីដែលទទួលភារកិច្ចតួនាទីជាអ្នកជួយប្រជារាស្ត្រសម្រាប់ធ្វើការអភិវឌ្ឍកិច្ចការណាមួយហើយប្រជារាស្ត្រមើលឃើញថាមន្ត្រីនោះបានអភិវឌ្ឍន៍ខ្លួនឯងជាជាងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួនគ្រប់គ្រងដែលវាបញ្ជាក់ថាការអភិវឌ្ឍដែលខ្វះដៃគូរ គឺមិនទទួលបាននូវប្រសិទ្ធភាពទេ។

## ១.២ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់តាមបែបវិមជ្ឈការ

ប្រទេសដែលអនុវត្តន៍តាមគោលការណ៍វិមជ្ឈការ នាំមកនូវការរីចម្រើនខាងសេដ្ឋកិច្ចកាន់តែខ្លាំងឡើងយ៉ាងឆាប់រហ័សក៏ដូចជាការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងដោះស្រាយក្នុងការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិ។ ហើយការផ្ដល់សេវាសាធារណៈកាន់តែប្រសើរឡើងថែមទៀតក្នុងនោះគឺមានការផ្ដោតយកចិត្តទុកដាក់ថែមទៀតទៅលើការធ្វើប្រតិភូកម្មថវិកាភារកិច្ច និងការទទួលខុសត្រូវផ្ទាល់ នៅក្នុងមូលដ្ឋាន។ ក្រៅពីនេះគឺ ការធ្វើឱ្យប្រសើរឡើងថែមទៀតក្នុងការធ្វើសេចក្ដីសម្រេចចិត្តទាំងឡាយបានត្រឹមត្រូវនៅតាមទីកន្លែង និងពេលវេលា ព្រោះមានការចូលរួមដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋានផ្ទាល់។

ហើយនរណា និងទទួលបានផលប្រយោជន៍ទាំងនោះ?

វិមជ្ឈការ ឃុំ សង្កាត់នេះ គឺ ត្រូវបានអ្នកនយោបាយទាំងឡាយផ្ដួចផ្ដើមឡើង និងអនុម័តយល់ស្របអំពីកំណែទម្រង់វិមជ្ឈការនេះដូចនេះអ្នកនយោបាយ និងទទួលបានប្រយោជន៍ពីវាជាមិនខាន(បើមិនដូច្នេះទេ ពួកគេនិងមិនយល់ព្រមធ្វើការកំណែទម្រង់វិមជ្ឈការនោះទេ)។ ក្រៅពីអ្នកនយោបាយទាំងនេះមានប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ព្រោះវិមជ្ឈការបានផ្ដល់នូវ អង្គភាពរដ្ឋបាលពោរពេញទៅដោយការប្រជែងខ្លាំងក្លាដែលអាចឆ្លើយតបបានច្រើនជាងមុនចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ព្រោះពួកគេចង់បានការគាំទ្រពីប្រជាពលរដ្ឋនៅមូលដ្ឋានរបស់គេ។

ដូចនេះ រាជរដ្ឋាភិបាលបានខិតខំធ្វើកំណែទម្រង់ការគ្រប់គ្រងវិមជ្ឈការ នៅឃុំ សង្កាត់ដើម្បីទទួលបាននូវសម្មទ្ធិផលជាច្រើនដូចជា ៖

- កាត់បន្ថយនូវភាពមិនអើពើចំពោះការអភិវឌ្ឍនៅមូលដ្ឋាន
- ជំរុញឱ្យមានការចូលរួម និងសកម្មភាពរួបរួមផ្សេងៗរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យកាន់តែខ្លាំងឡើង

ពង្រឹងការឆ្លើយតបឱ្យបានឆាប់រហ័ស និងយល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ

- បង្កើននូវលំហូរព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់មូលដ្ឋាន
- ធ្វើឱ្យគម្រោងអភិវឌ្ឍន៍កាន់តែមានចីរភាព
- ពង្រឹងនូវតម្លាភាព
- ជំរុញការទទួលខុសត្រូវឱ្យកាន់តែខ្ពស់
- ធ្វើឱ្យសម្រេចបាននូវកិច្ចការប្រឹងប្រែងថ្មីៗ
- កាត់បន្ថយឥទ្ធិពលអវិជ្ជមាន
- ធ្វើឱ្យកម្មវិធីអភិវឌ្ឍន៍កាន់តែរលូនជាងមុននៅមូលដ្ឋាន
- កាត់បន្ថយនូវសកម្មភាពពុករលួយ
- ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន

កត្តាទាំងអស់នេះហើយដែលធ្វើឱ្យប្រទេសកម្ពុជាយើងបានសម្រេចចិត្តធ្វើការគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ឃុំ សង្កាត់តាមបែបវិមជ្ឈការបន្តទៀត។

## ១.៣ ទិសដៅវិមជ្ឈការ

ការធ្វើវិមជ្ឈការនេះ គឺដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅ និងជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។ លើសពីនេះទៅទៀត ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ហើយធានាការអភិវឌ្ឍន៍ប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាឱ្យនៅជិតប្រជាពលរដ្ឋ និងយល់ច្បាស់អំពីតម្រូវការចាំបាច់របស់ពួកគាត់។

ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺ៖

- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គុណភាពនៃជីវភាពរស់នៅ។
- ធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់ សេវាជាមូលដ្ឋានផងដែរ។

## ១.៤ ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការ ឃុំ សង្កាត់

ឃុំ សង្កាត់មិនដែលធ្លាប់មានអាទិភាពទេ នៅក្នុងប្រទេសកម្ពុជាតាំងពីមុនការមកដល់នៃពួកអាណានិគមនិយមបារាំង។ នាឆ្នាំ១៨៧៥ ប្រព័ន្ធគ្រប់គ្រងរដ្ឋនៅក្រោមការគ្រប់គ្រងបារាំងផង និងសៀមផងកត្តា

ទាំងអស់ខាងលើនេះហើយជាបទពិសោធន៍ និងជាកញ្ចក់ឆ្លុះបញ្ចាំងអំពីសង្គមខ្មែរនាអតីតកាលយកធ្វើជាមូលដ្ឋានសិក្សាដើម្បីរៀបចំកែប្រែវាសនាអនាគតសង្គមជាតិខ្មែររបស់យើង។

ព្រះរាជក្រឹត្យចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ១៩០៨ បានបង្កើតនូវក្របខណ្ឌរដ្ឋបាលស៊ីវិលមួយដែល “ **ឃុំ** ” គេអាចនិយាយបានថាជាប្រភពនៃច្បាប់គ្រប់គ្រង “ **ឃុំ** ”របស់ប្រទេសកម្ពុជាដែលមានចែងអំពីនិយមន័យ “ **ឃុំ** ” ថារួមមានការបញ្ចូលគ្រួសារជាច្រើនរួមគ្នាឱ្យបង្កើតបានជាភូមិហើយភូមិជាច្រើនរួមគ្នាបង្កើតបានជាឃុំមួយ។

នៅឆ្នាំ ១៩១៩ ដល់ ១៩៤៣ ដើម្បីឱ្យមានភាពកាន់តែជិតស្និទ្ធរវាងប្រជាជន និង រាជការក្នុងការបំពេញការងាររបស់ខ្លួនឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពរដ្ឋាភិបាលអាណានិគមនិយមបារាំងបានផ្តួចផ្តើមឱ្យមានព្រះរាជក្រឹត្យចំនួនពីរទៀតគឺ ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩១៩ ដែលរដ្ឋាភិបាលកណ្តាលបានប្រគល់ប្រភពធនធានហិរញ្ញវត្ថុរបស់ខ្លួនដល់ឃុំជាអ្នកគ្រប់គ្រង និងផ្តល់អំណាចឱ្យមេឃុំជាអ្នករៀបចំអភិវឌ្ឍន៍មូលដ្ឋានឃុំរបស់ខ្លួនផ្ទាល់។ ហើយព្រះរាជក្រឹត្យមួយទៀតចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ១៩២៥ រដ្ឋាភិបាលអាណានិគមនិយមបារាំងផ្តល់ឱ្យមេឃុំនូវអំណាចក្នុងការរៀបចំចាត់ចែងការងារយុត្តាធិការការងារគ្រប់គ្រងរដ្ឋបាល ឃុំ ការងារហិរញ្ញវត្ថុដោយមានកម្រិតអត្រាពន្ធអាករ ឃុំកំណត់តម្លៃសម្រាប់ការងាររដ្ឋបាល និងធ្វើបុរប្រទាន។ ហើយព្រះរាជក្រឹត្យនេះក៏នៅបានផ្តល់ឱ្យឃុំបោះឆ្នោតរៀបចំនូវក្រុមជំនុំរបស់ខ្លួនដែលកើតចេញពីការបោះឆ្នោត ហើយជ្រើសរើសមេឃុំម្នាក់ដែលជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តសេចក្តីសម្រេចរបស់ក្រុមជំនុំដែលជានីតិបុគ្គល និងមានអាណត្តិ៤ឆ្នាំ ។ បន្ទាប់ពីការបោះឆ្នោតគេ សង្កេតឃើញថា មានការអភិវឌ្ឍយ៉ាងច្រើន និងប្រជាពលរដ្ឋរស់នៅសមរម្យដោយសារមានការចុះពង្រឹងនៅតាមមូលដ្ឋានរដ្ឋបាលកណ្តាល។

ក្នុងឆ្នាំ ១៩៤៣ ដោយសារប្រទេសមានសង្គ្រាមឈ្លានពានប្រព័ន្ធបោះឆ្នោតនៅឃុំត្រូវបានលុបចោលស្ទើរតែទាំងស្រុង ដោយដាក់ជំនួសការតែងតាំងមេឃុំ និងជំទប់ ពីសំណាក់អភិបាលខេត្ត និងដោយមានការយល់ព្រមពីរ៉េស៊ីដង់។ ព្រះរាជក្រម លេខ៨៤០នស ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៤៣ បានប្រកាសឱ្យឃុំ ដែលមានចំនួនប្រជាជនច្រើនមិនឱ្យមានការបោះឆ្នោតទេ ចំណែកឯ ឃុំដែលមានប្រជាជនតិចអនុញ្ញាតិឱ្យមានការបោះឆ្នោតដដែលប៉ុន្តែមិនត្រូវបានគេអនុវត្តទេ។ រហូតដល់ ឆ្នាំ១៩៤៨ ការបោះឆ្នោតជ្រើសរើសក្រុមជំនុំត្រូវបានផ្អាកទាំងស្រុង ។ ហើយនៅក្នុងឆ្នាំ ១៩៥៥ មានសារាចរណែនាំមួយឱ្យការបោះឆ្នោតមេឃុំឡើងវិញតែវាមិនសូវមានប្រសិទ្ធភាពដូចពីមុនទេ។

ដោយយល់ឃើញអំពីសារៈប្រយោជន៍នៃការបោះឆ្នោតជ្រើសរើសក្រុមជំនុំទើបនៅឆ្នាំ ១៩៥៩ មានព្រះរាជក្រមមួយទៀត លេខ៣៤០នស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៥៩ បានតម្រូវឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំ ជានីតិបុគ្គលដូចនៅឆ្នាំ ១៩២៥ សម្រាប់រយៈពេល ៤ ឆ្នាំ។ ហើយមេឃុំ និងជំទប់ ត្រូវជ្រើសរើសពីក្នុងក្រុមជំនុំដែលជាប់ឆ្នោតដោយយកតាមសម្លេងភាគច្រើន។ រចនាសម្ព័ន្ធដែលមាននៅពេលនោះគឺមាន មេឃុំ

ជំទប់ និង ស្មៀន គឺជាអ្នកដឹកនាំអនុវត្តផ្ទាល់( អង្គការប្រតិបត្តិ ឃុំ ) និងក្រុមជំនុំជាអ្នកដឹកនាំអង្គការបញ្ញត្តិឃុំ ដោយមានមេឃុំ ជាប្រធាននៃក្រុមជំនុំ។ ហើយ ចៅហ្វាយខេត្ត គឺជាអ្នកចេញដីកាខេត្តប្រកាសសុពលភាព និង តែងតាំងមេឃុំ និងក្រុមជំនុំតាមដីការបស់ខេត្ត។

តែមិនដល់រយៈពេល បីខែ ផងព្រះរាជក្រមនេះត្រូវបានគេដាក់ព្យួរទុកក្នុងរយៈពេលមិនកំណត់បន្ទាប់ពី បានធ្វើប្រជាមតិនៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ។ ដូចនេះ មេឃុំ និង ជំទប់ មិនត្រូវបានបោះឆ្នោតទេហើយនៅ តែមានការតែងតាំងពីអភិបាលខេត្ត ។ រហូតមកដល់ឆ្នាំ ១៩៦៩ តាមព្រះរាជក្រឹត្យ លេខ៣៨៣/៦៩CE/ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ១៩៦៩ បានប្រកាសកែប្រែឱ្យឈប់ធ្វើការបោះឆ្នោតជ្រើសរើសក្រុមជំនុំ មេឃុំ និង ជំទប់។ ហើយ មេឃុំ ជំទប់ ត្រូវបានតែងតាំងតាមរយៈដីកាខេត្តតាមសំណើរបស់អភិបាលស្រុក។ ចាប់ពីពេលនោះមក ឃុំលែង មានថវិកាផ្ទាល់ខ្លួន និងគ្មានការបោះឆ្នោតទៀតហើយ។

បន្ទាប់ពីសមាជជាតិលើកទី២០ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ១៩៦៥ គេបានស្នើសុំឱ្យប្តូរ ពាក្យ « **ឃុំ** » ទៅជា « **សង្កាត់** » សម្រាប់ហៅនៅក្នុងទីក្រុង ហើយរក្សាពាក្យ « **ឃុំ** » សម្រាប់ការហៅនៅ « **ខេត្ត** » ដដែល។

ហើយនៅឆ្នាំ ១៩៩៦- ១៩៩៧ ក្នុងនីតិកាលទី១ នៃរដ្ឋសភាក្រសួងមហាផ្ទៃដោយទទួលបានការណែនាំ គោលនយោបាយពីរាជរដ្ឋាភិបាលហើយបានសិក្សាស្រាវជ្រាវរៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានគ្រប់គ្រង ឃុំ សង្កាត់ឱ្យក្លាយជានីតិបុគ្គល។ សេចក្តីព្រាងច្បាប់នេះ ស្តីពីការគ្រប់ គ្រង ឃុំ សង្កាត់ និងសេចក្តីព្រាងច្បាប់ស្តី ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវបានរៀបចំរួចហើយប៉ុន្តែដោយសារស្ថានភាពនយោបាយ នៅកម្ពុជាមានបញ្ហាបន្តិចបន្តួចទើបមិនអាចយកមកពិភាក្សានៅក្នុងគណៈរដ្ឋមន្ត្រីបាន។

ក្រោយពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់នីតិកាលទី២ រួចរាល់ហើយក្រសួងមហាផ្ទៃបាន បន្តលើកយកសេចក្តីព្រាងច្បាប់ទាំងពីរខាងលើធ្វើសារជាថ្មីម្តងទៀត ដោយផ្អែកលើសភាពការណ៍ជាក់ស្តែងនៃ និន្នាការវិវត្តន៍នៃសង្គមជាតិ និងភាពចាំបាច់សម្រាប់លុបបំបាត់ភាពអសកម្មនៅមូលដ្ឋានការប្រឆាំងអំពើពុក រលួយកាត់បន្ថយភាពក្រីក្រ និងចង់ឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលនៅក្នុងដំណើរការអភិវឌ្ឍ សង្គមជាតិ ។ ហើយសេចក្តីព្រាងច្បាប់ទាំងពីរ ខាងលើនេះត្រូវបានដាក់ជូន រដ្ឋសភាពិនិត្យ និងអនុម័តនៅ ថ្ងៃទី ១២ ខែមករា ឆ្នាំ ២០០១ ។ ហើយការគ្រប់គ្រង ឃុំ សង្កាត់តាមបែបវិមជ្ឈការនៅកម្ពុជាក៏ចាប់ផ្តើមអនុវត្ត ឡើងវិញសារជាថ្មីទៀតចាប់ពីពេលនោះរហូតដល់ពេលបច្ចុប្បន្ន។

សរុបមក ប្រវត្តិនៃការអនុវត្តរដ្ឋបាល ឃុំ សង្កាត់នៃប្រទេសកម្ពុជាគេសង្កេតឃើញមានការកែប្រែជាញឹក ញាប់ក្នុងគោលបំណងធ្វើឱ្យមានការគ្រប់គ្រងនៅតាមមូលដ្ឋានឆ្លើយតបទៅនិងតម្រូវការប្រជាពលរដ្ឋ។ ក្នុងនោះ គេសង្កេតឃើញថាចាប់តាំងពីឆ្នាំ ១៨៨៩ ដល់ឆ្នាំ ១៩៥៣ មានការកែប្រែធំៗចំនួន៧ គឺនៅក្នុងឆ្នាំ ១៨៨៩ គឺ បារាំងបានកែសម្រួលរដ្ឋបាលទាំងស្រុងហើយ ឆ្នាំ ១៩០១ បារាំងបានបញ្ចូលគោលការណ៍ជ្រើសរើស មេឃុំ និង

ក្រុមជំនុំ។ បន្ទាប់នៅឆ្នាំ ១៩០២ បារាំងឱ្យប្រាក់កំរៃដល់មេឃុំ និង ក្រុមជំនុំ ហើយ ឆ្នាំ ១៩១៩ បារាំងបានប្រគល់ប្រភពធនធានហិរញ្ញវត្ថុឱ្យដល់ឃុំជាអ្នកគ្រប់គ្រង និងផ្តល់អំណាចឱ្យមេឃុំ ជាអ្នករៀបចំអភិវឌ្ឍន៍មូលដ្ឋានឃុំរបស់ខ្លួនផ្ទាល់។ នៅក្នុងឆ្នាំ១៩២៥ រដ្ឋាភិបាលអាណានិគមនិយមបារាំងបានផ្តល់ឱ្យមេឃុំ នូវអំណាចក្នុងការរៀបចំចាត់ចែងការងារ យុត្តាធិការការងារគ្រប់គ្រងរដ្ឋបាលឃុំ ការងារហិរញ្ញវត្ថុ ដើម្បីឱ្យការងារកាន់តែមានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន។

## ១.៥ តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

មាត្រា៤១នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានា ដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួម របស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិស្របតាម គោលនយោបាយទូទៅរបស់រដ្ឋ។

ផ្អែកតាមបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឱ្យនូវតួនាទីមុខងារ និងអំណាចមួយ ចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

### ១.៥.១ អំណាចរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំសង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយ មេឃុំ ចៅសង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានា ក្នុងក្របខ័ណ្ឌតួនាទីមុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ។ បើដីកាណាមួយដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹង ត្រូវបានចាត់ទុកជាមោឃៈដាច់ខាត។

អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់ មានន័យថារដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ អំណាច ប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឱ្យទៅមេឃុំ ចៅសង្កាត់ ជាអ្នក អនុវត្តក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

### ១.៥.២ តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទី ពីរ ប្រភេទ គឺ៖

- តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

➢ **ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន** រដ្ឋបាលឃុំសង្កាត់មានភារកិច្ច ៖

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យ កិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជា ពលរដ្ឋ។

➢ **ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ៖** រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្ត។ **ឧទាហរណ៍៖** ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាដើម។

### ១.៦ ព្រំដែននៃអំណាច

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខណ្ឌ អំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ។ នេះមាន ន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

➢ រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យ ៖

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ

- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

## ១.៧ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួនដោយផ្អែកតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់។

- ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក៥, ៧, ៩ ឬ១១នាក់ ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុង ឃុំ សង្កាត់។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ។

- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន០១រូប ដែលហៅថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺ ជាមេឃុំ ចៅសង្កាត់។

- ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់។ ស្ត្រី និងបុរស អាចត្រូវបានជ្រើសរើសឱ្យធ្វើជាមេឃុំ ចៅសង្កាត់ ដោយផ្អែកតាមលទ្ធផលនៃការបោះឆ្នោត។

- មេឃុំ ចៅសង្កាត់មានជំនួយការ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់ រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។

- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិ ម្នាក់សម្រាប់ភូមិនីមួយៗ ក្នុងឃុំ សង្កាត់របស់ខ្លួនដោយអនុវត្ត តាមសេចក្តីណែនាំលេខ០០៤ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែងការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ចរបៀបរបបធ្វើការងាររបស់ភូមិ។ មេភូមិ គឺជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់។ មេភូមិត្រូវមានជំនួយការរបស់ខ្លួន០២រូប ម្នាក់ជាអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ។

- មេឃុំ ចៅសង្កាត់អាចចាត់តាំងបង្កើតគណៈកម្មាធិការបានតាមការចាំបាច់។ គណៈកម្មាធិការនីមួយៗមានសមាជិកយ៉ាងតិច ០៣នាក់ ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនេះអាចយកសមាជិកណាម្នាក់ ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមាន សិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួនក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យធ្វើជាប្រធានក៏បាន។

- យុំ សង្កាត់នីមួយៗមានស្មៀនមួយរូប ដែលត្រូវបានតែងតាំង និងបម្រើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋបាលក្រសួងមហាផ្ទៃ។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់។ នៅក្នុងការបំពេញមុខងាររបស់ខ្លួនស្មៀនឃុំ សង្កាត់ត្រូវតែអព្យាក្រឹត្យ មិនលម្អៀង ហើយត្រូវប្រកាន់ឥរិយាបទឱ្យបានស្មើៗគ្នាចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សា គ្រប់រូបដោយមិនប្រកាន់និន្នាការនយោបាយ និងចំពោះគណៈ កម្មាធិការនានា។




**រូបភាពដកស្រង់ចេញពីៈ** ក្រសួងមហាផ្ទៃ **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ**

## ១.៨ ទំនាក់ទំនងអន្តររដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

### ១.៨.១ ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់

- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗធ្វើការ ប្រាស្រ័យទាក់ទងចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នានានៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់របស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗធ្វើកិច្ចសហការជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់នានាដើម្បីជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក សំដៅលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងការធ្វើកិច្ចសហប្រតិបត្តិការនេះត្រូវអនុវត្តតាមកិច្ចព្រមព្រៀង ឬតាមការចាត់ចែងរួមគ្នា
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗអាចផ្តល់យោបល់ និងផ្តល់សេវាគាំទ្រផ្នែករដ្ឋបាលបច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងៗទៀតទៅតាមការស្នើសុំ។

### ១.៨.២ ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអង្គបោះឆ្នោតរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការប្រាស្រ័យទាក់ទងចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ស្នើសុំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ ជាពិសេសតម្រូវការនានាដែលរដ្ឋបាលឃុំ សង្កាត់ពុំអាចមានលទ្ធភាពឆ្លើយតបបានក្នុងក្របខ័ណ្ឌសិទ្ធិអំណាច មុខងារ និង ធនធានរបស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើកិច្ចសហការជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមកសំដៅដល់ការ លើកកម្ពស់ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព
- ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបាននូវចំណូលចែករំលែកជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ក្រុមប្រឹក្សាឃុំ សង្កាត់អាចចូលរួមកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទៅតាមការស្នើសុំ
- ក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ក្រុមប្រឹក្សាឃុំ សង្កាត់អាចស្នើសុំការគាំទ្រផ្នែករដ្ឋបាល បច្ចេកទេស និងធនធានពីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈ មេឃុំ ចៅសង្កាត់ ដាក់ជូនអភិបាលរាជធានី ខេត្ត និង ក្រុង នូវដីកា និង សេចក្តីសម្រេចរបស់ខ្លួនដើម្បីពិនិត្យនីត្យានុកូលភាព ៖

- ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងស្រុក ដាក់ជូនអភិបាលខេត្ត
- ចំពោះក្រុមប្រឹក្សាសង្កាត់ ក្នុងក្រុង ដាក់ជូនអភិបាលក្រុង
- ចំពោះក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានី ដាក់ជូនអភិបាលរាជធានី

### ១.៨.៣ ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងាររបស់រដ្ឋ

- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើទំនាក់ទំនងជាផ្លូវការជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរ និងភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានាតាមរយៈអភិបាល រាជធានី ខេត្ត។

- ក្រសួង ស្ថាប័ននានា អាជ្ញាធរ និងភ្នាក់ងារនានារបស់រាងជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានា អាចធ្វើទំនាក់ទំនង និងកិច្ចសហការដោយផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ តាមការចាំបាច់ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលរាជធានី ខេត្ត។

- អភិបាលរាជធានី ខេត្ត ត្រូវសម្របសម្រួលរវាងឃុំ សង្កាត់ពីរ ឬច្រើនអំពីបញ្ហាណាមួយដែលមានភាពប្រទាញប្រទង់គ្នា ឬមានជម្លោះជាមួយគ្នា ហើយដែលឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន។

- អភិបាលរាជធានី ខេត្ត ត្រូវសហការ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ឬភ្នាក់ងារពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាដែលមានភាពប្រទាញប្រទង់គ្នា ឬមានជម្លោះពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋចំពោះឃុំ សង្កាត់ ឬសេចក្តីសម្រេច ឬសកម្មភាពរបស់ក្រសួង ស្ថាប័ន ឬភ្នាក់ងារទាំងនោះ។

## ១.៩ ការតាមដាន ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍

- អភិបាលរាជធានី ខេត្ត ទទួលបានប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្នុងការតាមដានការត្រួតពិនិត្យ និងការគាំទ្រលើការប្រើប្រាស់អំណាច និងការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់រួមទាំងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់។

- ឃុំ សង្កាត់ណាដែលមិនបាន បំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់។

- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា៥៧ និង មាត្រា៥៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) ក្នុងករណី ៖

- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើអន្តរាគមន៍ហើយតែមិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវក្នុងអំឡុងពេល៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវនោះ ជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់នោះមិនអាចបំពេញបាន ឬ
- ក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញផ្ទុយនឹងនយោបាយរាជរដ្ឋាភិបាល ។[4]

[4] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិជ្ជការ ទំព័រ២០

# ជំពូកទី២
# ដំណើរការនៃការគ្រប់គ្រង
# កិច្ចការរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី២

# ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ២.១ លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់

### ២.១.១ និយមន័យលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់គឺជាលិខិតដែលកំណត់នូវវិធានបទប្បញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តកិច្ចការនានា។

### ២.១.២ ប្រភេទលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ រួមមាន ដីកា និង សេចក្តីសម្រេច។

**ដីកា** ឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបានកំណត់នូវបទប្បញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើង សំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាពមិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន ។

**ដីកា** ឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់នឹងលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។ ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

**សេចក្តីសម្រេច** ឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើត ការតែងតាំងការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។

សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែលទៅនឹងដីកាឃុំ សង្កាត់ដែរប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់។

សេចក្តីសម្រេច ឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាន នានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ។ សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ក្នុងករណីប្រធានសក្តិ និងករណីបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានមេឃុំ ចៅសង្កាត់អាចចេញសេចក្តីសម្រេចដើម្បី ដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនេះនឹងត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាប់ដើម្បីពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវតាមច្បាប់។

## ២.២. លិខិតរដ្ឋបាលឃុំ សង្កាត់

### ២.២.១ និយមន័យលិខិតរដ្ឋបាល

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបបានចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានាក្នុងគោលបំណងជូនព័ត៌មានណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំងបុគ្គលណាមួយឱ្យទៅបំពេញបេសកកម្ម។

### ២.២.២ ប្រភេទលិខិតរដ្ឋបាល

លិខិតរដ្ឋបាល ឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការ រួមមាន ៖

(១)លិខិតស្នើ (២)សេចក្តីជូនដំណឹងឬលិខិតជូនដំណឹង (៣)លិខិតអញ្ជើញ (៤)លិខិតបញ្ជាបេសកកម្ម (៥) របាយការណ៍ (៦) កំណត់ហេតុ (៧) លិខិតផ្ទេរសិទ្ធិ និង (៨) ដីកាអម។

**លិខិតស្នើ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

**សេចក្តីជូនដំណឹងឬលិខិតជូនដំណឹង** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បី ធ្វើការទំនាក់ទំនងជាមួយបុគ្គល ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងឱ្យសាធារណជនបានដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។

**លិខិតអញ្ជើញ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គល ឬអង្គភាពទាំងនោះដោយមានបញ្ជាក់ឈ្មោះ និងឋានៈ(អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធពិធីកាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ (និងអាច មានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ)។

**លិខិតបញ្ជាបេសកកម្ម** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ឱ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះមានភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។

ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយសម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែងកាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងឮអំពីការចេញដំណើរ និងការមកដល់ពីដំណាក់មួយទៅដំណាក់មួយទៀត។

នៅពេលត្រឡប់មកវិញត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបានជ្រាបអំពីលទ្ធផល ឬបញ្ហា សំខាន់ៗដែលខ្លួនបានទៅចូលរួម។

**របាយការណ៍** គឺជាសេចក្តីរាយការណ៍អំពីសកម្មភាពដំណើរការ និងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែល រដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬ ឃុំ សង្កាត់បានចាត់តាំងឱ្យទៅបំពេញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។

ទម្រង់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ០៣៥ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រៅពីទម្រង់របាយការណ៍ប្រចាំខែ និងទម្រង់របាយការណ៍ប្រចាំឆ្នាំខាងលើនេះ ឃុំ សង្កាត់អាចបង្កើត និងប្រើប្រាស់ទម្រង់របាយការណ៍ផ្សេងទៀតសម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។

**កំណត់ហេតុ** គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងការឯកភាពលើសកម្មភាព ដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយ ដែលបានកើតឡើងជាក់ស្តែងដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

**លិខិតផ្ទេរសិទ្ធិ** គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយល័ក្ខណ៍អក្សរប្រគល់សិទ្ធិឱ្យជំទប់ ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទីក្នុងអំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។

**ដីការអម** គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងផ្ញើអមភ្ជាប់ជាមួយសំណុំលិខិតដែលត្រូវផ្ញើចេញទៅឱ្យអង្គភាព ក្រសួង ស្ថាប័នណាមួយដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត(ឯកសារ)លើនោះ។ ឃុំ សង្កាត់ប្រើដីការអម ដើម្បីជៀសវាងការបាត់បង់ឯកសារដែល រដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ។[5]

## ២.៣ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

៖ អនុលោមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានកំណត់ថា មុនចាប់ផ្តើមការងារក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់វិធានទាំងឡាយសម្រាប់អង្គប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។[6]

### ២.៣.១ អំពីការរៀបចំបទបញ្ជាផ្ទៃក្នុង

បន្ទាប់ពីកិច្ចប្រជុំប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់ត្រូវចាត់ចែងរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ក្រុម

[5] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ទំព័រ ២៥

[6] មាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ប្រឹក្សា ឃុំ សង្កាត់ និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើឡើងជា ទម្រង់ដីកា និងពិភាក្សាអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងយូរបំផុតរយៈពេល ៣០ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំដំបូងមុននឹងឈានទៅអនុវត្តកិច្ចការផ្សេងទៀត។

**២.៣.២. ការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**

ស្មៀនឃុំ សង្កាត់ត្រូវរៀបចំដាក់ជូនសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅមេឃុំ ចៅសង្កាត់របស់ខ្លួនដើម្បីស្នើសុំពិនិត្យ និងឯកភាពជាបឋមលើសេចក្តីព្រាងនេះមុននឹងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំកិច្ចប្រជុំពិភាក្សា និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយអនុវត្តស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលកំណត់ថា ការប្រជុំអនុម័តបទបញ្ជាផ្ទៃក្នុងនេះនឹងយកជាការលុះត្រាតែ វត្តមានសមាជិកក្រុមប្រឹក្សាមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវបានអនុម័តដោយ សំឡេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងមូល។

ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវធ្វើកំណត់ហេតុស្តីពី កិច្ចប្រជុំអនុម័តបទបញ្ជាផ្ទៃក្នុងនេះឱ្យច្បាស់លាស់ និងត្រឹមត្រូវ។

ក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តរួចហើយ ស្មៀនឃុំ សង្កាត់ត្រូវរៀបចំដាក់ជូនប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ចុះហត្ថលេខា លើដីកាស្តីពីបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាឃុំ សង្កាត់។

ស្មៀនឃុំ សង្កាត់ត្រូវថតចម្លងចែកជូនគ្រប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ព្រមទាំងត្រូវផ្ញើជូនអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរក្សាទុកជាឯកសារក្នុងរដ្ឋបាលឃុំ សង្កាត់សាមី។

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនមិនទាន់ពេលវេលាដែលបានកំណត់ ក្រុមប្រឹក្សាឃុំ សង្កាត់នោះ ត្រូវអនុវត្តតាមគំរូបទបញ្ជាផ្ទៃក្នុងដែលបានភ្ជាប់ជាមួយសេចក្តីណែនាំស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ លេខ០១៤ ស.ណ.ន ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ឬអនុវត្តតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ចាស់ដែលទើបបញ្ចប់អាណត្តិ។

**២.៣.៣ ការពិនិត្យនីត្យានុកូលភាពនៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**

ដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលអនុម័តរួចហើយត្រូវថតចម្លងចំនួនមួយច្បាប់ជូនអភិបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីថ្ងៃអនុម័ត ដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

ទីចាត់ការផែនការ និងវិនិយោគសាលារាជធានីខេត្ត ត្រូវធ្វើជាសេនាធិការក្នុងការពិនិត្យ និងការផ្តល់យោបល់លើការពិនិត្យនីត្យានុកូលភាពដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ក្នុងករណីពិនិត្យឃើញថា ខ្លឹមសារកែប្រែ និងការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយ មានលក្ខណៈផ្ទុយពីគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានជាធរមាន អភិបាលរាជធានី ខេត្តត្រូវធ្វើការណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់នោះធ្វើការកែតម្រូវថ្មីឡើងវិញជាបន្ទាន់។ ក្រោយពីបានទទួលការណែនាំពីអភិបាលរាជធានី ខេត្ត មេឃុំ ចៅសង្កាត់ត្រូវធ្វើការពិនិត្យ និងកែតម្រូវឡើងវិញហើយដាក់ជូន ក្រុមប្រឹក្សាពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញបន្ទាប់។

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនធ្វើការកែតម្រូវឡើងវិញតាមការណែនាំនោះអភិបាលរាជធានីខេត្តត្រូវចាត់វិធានការស្របតាមគោលការណ៍បែបបទ និងនីតិវិធីដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តកំណត់។

## ២.៤ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ៖

- មាត្រា៧៣ ៖ ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ និងព្រទ្យសម្បត្តិផ្ទាល់។
- មាត្រា៨២៖ ឃុំ សង្កាត់ត្រូវបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងតាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន។

**ប្រភពចំណូលឃុំ សង្កាត់**

ប្រភពចំណូលឃុំ សង្កាត់សំខាន់ៗមាន ៣ គឺ ៖

- ចំណូលផ្ទាល់
- ចំណូលពីមូលនិធិឃុំ សង្កាត់ និង
- ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ។

### ២.៤.១ ចំណូលផ្ទាល់

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពី ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ។

**បញ្ជាក់** ៖ ប្រភេទកម្រិត និងរបៀបនៃការប្រមូលចំណូលផ្ទាល់នេះនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែក។ បច្ចុប្បន្ននេះឃុំ សង្កាត់មិនអាចអនុវត្ត ការប្រមូលចំណូលសារពើពន្ធនេះបានឡើយដោយហេតុថាមិនទាន់មានច្បាប់ស្តីពីការប្រមូលចំណូលនេះ។

### ២.៤.២ ចំណូលពីមូលនិធិឃុំ សង្កាត់

ចំណូលពីមូលនិធិឃុំ សង្កាត់គឺជាចំណូលដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ឱ្យទៅឃុំ សង្កាត់នីមួយៗដែលក្នុងនោះ មានចំណែកសម្រាប់ចំណាយផ្នែករដ្ឋបាល និងចំណាយផ្នែកអភិវឌ្ឍន៍ឃុំ សង្កាត់។

### ២.៤.៣ ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ

ចំណូលការអនុវត្តមុខងារជាភ្នាក់ងារ គឺជាចំណូលដែលបានមកពីការបំពេញភារកិច្ចដោយ ឃុំ សង្កាត់ជំនួសមុខឱ្យក្រសួង ស្ថាប័ន ឬអង្គភាព នានារបស់រដ្ឋទៅតាមការព្រមព្រៀងគ្នា។

ក្រៅពីចំណូលសំខាន់ៗទាំង បី ខាងលើនេះឃុំ សង្កាត់មានចំណូលផ្សេងៗទៀតដូចជា ៖

- ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន
- ចំណូលពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា ។

ឃុំ សង្កាត់ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិទាំងនេះយ៉ាងហ្មត់ចត់ដើម្បីធានាថាការប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់ធ្វើឡើងឱ្យបានត្រឹមត្រូវមានតម្លាភាពសន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់។

## ២.៥ របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់

របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់មាន ៣ ប្រភេទ ៖

- របាយការណ៍ស្តីពីចំណូលចំណាយថវិកាប្រចាំខែ
- របាយការណ៍ស្តីពីចំណូលចំណាយថវិកាប្រចាំឆមាស
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

## ២.៦ កិច្ចលទ្ធកម្មឃុំសង្កាត់

កិច្ចលទ្ធកម្ម គឺជាដំណើរការលទ្ធកម្មចាប់ពីពេលដែលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញ សំណង់ ឬសេវាកម្ម។ លទ្ធកម្ម សំដៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ ឬសេវាកម្មតាមរយៈវិធីសាស្ត្រដែលបានកំណត់។

### ២.៦.១ គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្ម

- លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និងលទ្ធកម្មទំនិញត្រូវអនុវត្តក្នុងលក្ខណៈមួយដែលមានតម្លាភាពប្រសិទ្ធភាព និងសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាព
- អ្នកទទួលការ អ្នកផ្តល់សេវាកម្ម និងអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នាដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ។

**២.៦.២ សមាសភាពគណៈកម្មការលទ្ធកម្ម**

- មេឃុំ ចៅសង្កាត់ ជាប្រធាន
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ២រូប ជាសមាជិក

ស្មៀនឃុំ សង្កាត់បំពេញតួនាទីជាលេខាធិការឱ្យគណៈកម្មការ លទ្ធកម្មឃុំ សង្កាត់។

**២.៦.៣ វិធីសាស្ត្រលទ្ធកម្ម**

- ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ(ជាសាធារណៈ)
- ការស្ទង់តម្លៃក្នុងស្រុក
- ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់(ការចរចាតម្លៃផ្ទាល់)។

**២.៦.៤ ការទូទាត់**

មេឃុំ ចៅសង្កាត់មិនត្រូវធ្វើការទូទាត់ឱ្យអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ជាមុនឡើយ។

ការទូទាត់ត្រូវធ្វើឡើង តែនៅពេលណាដែល ទំនិញត្រូវបានប្រគល់ទទួលត្រឹមត្រូវ និងការងារសំណង់ និងការងារសេវាកម្មត្រូវបានបំពេញត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា។

## ២.៧ ប្រព័ន្ធកសាងផែនការឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា៦០ ចែងថា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យកម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។[7]

ផែនការឃុំ សង្កាត់រួមមាន ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**❖ គោលការណ៍សំខាន់ៗនៃការកសាងផែនការឃុំ សង្កាត់**

ការកសាងផែនការឃុំ សង្កាត់ត្រូវផ្អែកតាមគោលការណ៍សំខាន់ៗ ដូចខាងក្រោម ៖

- **ការចែករំលែកព័ត៌មាន ៖** ក្នុងដំណើរការកសាងផែនការត្រូវមាន ការចែករំលែកព័ត៌មានរវាងរដ្ឋបាលថ្នាក់ផ្សេងៗគ្នារវាងប្រជាពលរដ្ឋ រវាងការិយាល័យ អង្គភាព អង្គការជាតិ អន្តរជាតិ និងដៃគូនានា ព្រមទាំងវិស័យឯកជន ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- **តម្លាភាព ៖** ការកសាងផែនការត្រូវធ្វើឡើងស្របតាមបែបបទ នីតិវិធី គោលការណ៍ណែនាំ មិនមានការលាក់លៀម គ្រប់អ្នកពាក់ព័ន្ធបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានា ហើយព័ត៌មានជុំវិញការធ្វើសេចក្តីសម្រេចចិត្តនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។
- **សង្គតិភាព និងសុខដុមនីយកម្ម ៖** ផែនការត្រូវរៀបចំឡើងមានលំដាប់លំដោយត្រឹមត្រូវ ស៊ីសង្វាក់

[7] មាត្រា ៦០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

និងមានលក្ខណៈសមស្របសម្រាប់គ្រប់អ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សាឃុំ សង្កាត់។ ផែនការឃុំ សង្កាត់ត្រូវស្របទៅនឹងគោលនយោបាយជាតិផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងផែនការអភិវឌ្ឍន៍ក្រុង ស្រុក។

• **ការចូលរួមពិគ្រោះយោបល់** ៖ ជាទូទៅ ក្នុងដំណើរការកសាង ផែនការ ត្រូវមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

• **ការឆ្លើយតបនឹងតម្រូវការ** ៖ ផែនការឃុំ សង្កាត់ពិសេស ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ឬគម្រោងវិនិយោគ ត្រូវតែឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

• **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**៖ ក្នុងដំណើរការកសាង និងអនុវត្តផែនការត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សា និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ (គ.ផ.ថ) ត្រូវធ្វើសេចក្តីសម្រេចអំពីការអភិវឌ្ឍមូលដ្ឋានដោយឈរលើតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងត្រូវផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីហេតុផលនៃការធ្វើសេចក្តីសម្រេចរបស់ខ្លួន ចំពោះការអភិវឌ្ឍមូលដ្ឋានទាំងនោះ ហើយព្រមទាំងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ អំពីការសម្រេចរបស់ខ្លួនរួមទាំងផលវិបាកដែលកើតឡើងពីការសម្រេចទាំងនេះ។

• **ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម** ៖ ក្នុងដំណើរការកសាង និងអនុវត្តផែនការត្រូវធានានូវប្រសិទ្ធភាពត្រូវចូលរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ដើម្បីធានាឱ្យមានប្រសិទ្ធភាពចាំបាច់ត្រូវកំណត់ឱ្យបាននូវ តម្រូវការដែលមានអាទិភាពខ្ពស់បំផុត និងត្រូវសម្រេចប្រើប្រាស់ធនធានសម្រាប់ឆ្លើយតបតម្រូវការជាអាទិភាពទាំងនេះប្រកបដោយភាពសន្សំសំចៃខ្ពស់ដោយត្រូវធ្វើយ៉ាងណាឱ្យការចំណាយតិចបំផុត និងទទួលផលបានច្រើនបំផុតតាមដែលអាចធ្វើបាន។

• **ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន** ៖ ក្នុងដំណើរការកសាង និងអនុវត្តផែនការឃុំ សង្កាត់ត្រូវចូលរួមចំណែកក្នុងការការពារធនធានធម្មជាតិ និងបរិស្ថាន សំដៅធានាបាននូវនិរន្តរភាព ធនធានធម្មជាតិ និងបរិស្ថាន ពោលគឺ មិនបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានក្នុងឃុំ សង្កាត់ឡើយ។

• **ការធានាសមធម៌** ៖ ក្នុងដំណើរការកសាង និងអនុវត្តផែនការឃុំ សង្កាត់ត្រូវធានាឱ្យមានការចូលរួម និងផ្តល់ផលប្រយោជន៍ដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសស្ត្រី កុមារ ជនក្រីក្រ ជនពិការ ក្រុមជនភាគតិច និងជនងាយរងគ្រោះដែលមាននៅក្នុងឃុំ សង្កាត់។

## ២.៨ តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

យន្តការ ដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គឺ ៖

### ២.៨.១ ក្រុមប្រឹក្សាឃុំ សង្កាត់

•ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលឃុំ សង្កាត់ដោយធានាឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋពិសេស ស្ត្រី កុមារ ជនពិការ យុវជន និងជនងាយរងគ្រោះជាដើម។

• ពិនិត្យ និងអនុម័តរាល់ការធ្វើវិសោធនកម្មផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

• តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការសម្រេចបាននូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

### ២.៨.២ មេឃុំ ចៅសង្កាត់

- ដឹកនាំការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់
- ដឹកនាំការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលឃុំ សង្កាត់

• ដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់ ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។

### ២.៨.៣ គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់(គ.ផ.ថ)

• ជួយមេឃុំ ចៅសង្កាត់ ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដោយអនុវត្តតាមបែបបទនីតិវិធីដូចមានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងសេចក្តីណែនាំស្តីពី ការរៀបចំ និងកសាងកម្មវិធីវិនិយោគ បីឆ្នាំ រំកិលឃុំ និងសង្កាត់។

យន្តការទាំងបីខាងលើ គឺជាយន្តការស្នូលក្នុងការចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធី វិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ដើម្បីធានាឱ្យផែនការអភិវឌ្ឍន៍ និងកម្មវិធី វិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់មានគុណភាពចាំបាច់ត្រូវមានយន្តការ គាំទ្រ ដែលរួមមាន ៖

### ២.៨.៤ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក)

• ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រមូលវិភាគព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងបញ្ហាតម្រូវការរបស់នារី និងកុមារដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

• ទាក់ទាញការគាំទ្រដើម្បីឱ្យអ្នកពាក់ព័ន្ធនានា ពិសេសស្ត្រី ជនពិការ យុវវ័យ និងជនងាយរងគ្រោះ

នានាបានចូលរួមក្នុងការ ធ្វើសេចក្ដីសម្រេចចិត្តលើការអភិវឌ្ឍមូលដ្ឋាន

- ចូលរួមផ្ដល់ព័ត៌មាន និងជំរុញឱ្យមានការយកចិត្តទុកដាក់លើ បញ្ហាស្ត្រី កុមារ និងជនងាយរងគ្រោះនានាដែលមានក្នុងដែនសមត្ថកិច្ចខ្លួននៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

- សហការបំពេញការងារតាមសំណូមពរពី គ.ផ.ថ ដើម្បីកសាង ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**២.៨.៥ មន្ទីរផែនការរាជធានី ខេត្ត**

- គាំទ្របច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដូចជា ការងារស្រង់ទិន្នន័យពីមូលដ្ឋានភូមិ ឃុំ សង្កាត់ការងារចងក្រងកម្រងព័ត៌មាន ស្ថានភាពឃុំ សង្កាត់ ប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងព័ត៌មានផ្សេងៗទៀត។

- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត និងទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្តក្នុងការបណ្ដុះបណ្ដាលអំពីបច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេស តាមដាន និងវាយតម្លៃលទ្ធផលអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

- សហការផ្ដល់ការគាំទ្រ បច្ចេកទេសអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងបុគ្គលិកសំខាន់ៗរបស់ឃុំ សង្កាត់តាមសំណើពីអ្នកពាក់ព័ន្ធ។

**២.៨.៦ ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

- ផ្ដល់ការបណ្ដុះបណ្ដាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដោយមានកិច្ចសហការ ជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស រាជធានី ខេត្ត មន្ទីរផែនការរាជ ធានី ខេត្ត និងឬអង្គភាពជំនាញក្នុងករណីចាំបាច់

- ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ទុកជាឯកសារ

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំនិងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធី វិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**២.៨.៧ ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ឬការិយាល័យផែនការ និងអភិវឌ្ឍន៍**

• ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការវិភាគ វាយតម្លៃ និងរៀបចំ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

• ជួយទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ដើម្បីពិនិត្យ និងលើកយោបល់ជូនអភិបាលរាជធានី ខេត្ត អំពីការធ្វើអនុលោមភាពផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

• ជួយអភិបាលក្រុង(សង្កាត់ក្នុងក្រុង)អំពីការធ្វើអនុលោមភាព ផែនការអភិវឌ្ឍន៍សង្កាត់

• សម្របសម្រួល និងប្រមូលឯកសារដើម្បីបញ្ជូនទៅអង្គភាពពាក់ព័ន្ធ សិក្សា វាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និងតម្រូវការគាំទ្រនានា

• ជួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់

• គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំការកសាង និងការអនុវត្ត ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**២.៨.៨ ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ**

• ជួយសម្របសម្រួល និងជំរុញអាជ្ញាធរភូមិ ឃុំ សង្កាត់ ក្នុងការស្រង់ទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់

• ជួយ គ.ផ.ថ ក្នុងការវិភាគព័ត៌មានស្ថានភាព និងពិន្ទុវិស័យទិន្នន័យភូមិ ឃុំ សង្កាត់។

**២.៨.៩ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានាថ្នាក់រាជធានី ខេត្ត**

ទទួលខុសត្រូវផ្តល់ជំនួយបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងជំនាញរបស់ខ្លួនដល់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដូចជា យេនឌ័រ ការប្រែប្រួល អាកាសធាតុការគ្រប់គ្រងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលសល់ពីសង្គ្រាម ពិការភាព។ល។

**២.៨.១០ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា**

• ចូលរួមជាតំណាងឱ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ដូចជាតំណាងឱ្យស្ត្រី កុមារ យុវជន ជនក្រីក្រ ជនជាតិដើមភាគតិច។ល។

• ចូលរួមផ្តល់ចំណេះដឹង និងគំនិតផ្សេងៗក្នុងការរៀបចំផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

• ចូលរួមក្នុងការពិភាក្សា និងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធ នឹងដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**២.៨.១១ ប្រជាពលរដ្ឋ**

ក្នុងដំណើរការ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ត្រូវចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីកំណត់បញ្ហា និងតម្រូវការអាទិភាពនានាក្នុងសហគមន៍ និងមូលដ្ឋានខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់សាមីខ្លួននីមួយៗ។

## ២.៩ ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់មាន ៣ ជំហាន គឺ ៖

ជំហានទី១ ៖ ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់

ជំហានទី២ ៖ ការរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

- **ជំហានទី១ ៖ ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់**

**➢ ប្រជុំនៅឃុំ សង្កាត់លើកទី១**

- គ.ផ.ថ ជួបប្រជុំនៅឃុំ សង្កាត់ ដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាពឃុំ សង្កាត់ និង ទិន្នន័យ ឬព័ត៌មាន ឬប្រើឧបករណ៍វិភាគផ្សេងៗក្នុងការកំណត់ អំពីបញ្ហាទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ។ កិច្ចប្រជុំនេះអាចវិភាគស្ថានភាព ឬបញ្ហានានាដែលឃុំ សង្កាត់កំពុងជួបប្រទះ។

**➢ ប្រជុំនៅតាមភូមិ**

- តំណាងភូមិដែលជាសមាជិក គ.ផ.ថ ស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយទាំងឡាយដែល ពាក់ព័ន្ធនឹងភូមិរបស់ខ្លួន
- នៅក្នុងការប្រជុំតាមភូមិនេះ តំណាង គ.ផ.ថ ត្រូវ ៖

- បង្ហាញអំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយដល់ប្រជាពលរដ្ឋដែលបានចូលរួម

- ពិភាក្សា និងធ្វើសុពលភាពបញ្ហាទីតាំងនៃបញ្ហា មូលហេតុបញ្ហា តម្រូវការ និងដំណោះស្រាយ

- បែងចែកអ្នកចូលរួមជាក្រុមដើម្បីពិភាក្សា និងកំណត់អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ ឧបសគ្គ និង ដំណោះស្រាយបន្ថែម

**➢ ប្រជុំនៅឃុំ សង្កាត់លើកទី២**

•បន្ទាប់ពីបញ្ចប់ការប្រជុំតាមភូមិ គ.ផ.ថ ជួបប្រជុំនៅឃុំ សង្កាត់ដើម្បីបូកសរុបបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និង ដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា។ ក្នុងការបូកសរុបនេះ គ.ផ.ថ ត្រូវពិនិត្យ និងបន្សុីគ្នានូវរាល់បញ្ហា តម្រូវការនានា របស់ប្រជាពលរដ្ឋតាមភូមិនីមួយៗទូទាំង ឃុំ សង្កាត់។

• គ.ផ.ថ ស្រង់លទ្ធផលនៃការពិនិត្យ ពិភាក្សា ចូលក្នុងតារាង ការបូកសរុបបញ្ហា តម្រូវការ និងដំណោះស្រាយរបស់ឃុំ សង្កាត់។

**ជំហានទី២ ៖ ការរៀបចំ និងការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

**➢ ការរៀបចំស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ឃុំ សង្កាត់**

ផ្អែកទៅលើលទ្ធផលនៃការវិភាគស្ថានភាពត្រូវរៀបចំបរិយាយអំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ ឃុំ សង្កាត់។

**➢ ការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ សង្កាត់**

ផ្អែកលើការ ពិភាក្សានិងរៀបចំចក្ខុវិស័យគោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

បន្ទាប់មក គ.ផ.ថ ស្រង់ចក្ខុវិស័យ គោលបំណង គោលដៅ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍ ។

**➢ ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេល៥ឆ្នាំ**

ផ្អែកតាមក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដោយ មានស្មៀន និង គ.ផ.ថ ជាជំនួយការ ត្រូវរៀបចំកម្មវិធីអភិវឌ្ឍន៍ មូលដ្ឋានរយៈពេល៥ឆ្នាំរបស់ឃុំ សង្កាត់ ដោយកំណត់អំពី ៖

- ក្របខ័ណ្ឌវិនិយោគ
- ក្របខ័ណ្ឌផ្តល់សេវា និង
- ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា

**➢ ការពិនិត្យ និងសម្រេចក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធី អភិវឌ្ឍន៍ មូលដ្ឋាន**

មេឃុំ ចៅសង្កាត់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួននូវសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីពិនិត្យ និងសម្រេច។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់កោះប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងសម្រេចក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍ មូលដ្ឋាន។ ឯកសារទាំងពីរនេះ គឺជាមូលដ្ឋានសម្រាប់ការរៀបចំ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**➢ ការរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តផែនការ អភិវឌ្ឍន៍ឃុំ សង្កាត់**

គ.ផ.ថ ត្រូវរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែលរួមមាន ៖

- ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍

-ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន។

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន ៖

- ជាប្រចាំឆ្នាំ តាមរយៈការរៀបចំ និងការអនុវត្តកម្មវិធីវិនិយោគបី ឆ្នាំរំកិលឃុំ សង្កាត់

- នៅពាក់កណ្តាលអាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់

- នៅក្នុងរយៈពេល៦ខែ មុនពេលបញ្ចប់អាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់។

**៦ ការចងក្រងសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍**

បន្ទាប់ពីរៀបចំចប់សព្វគ្រប់នូវព័ត៌មាន និងតារាងនានាខាងលើ គ.ផ.ថ ត្រូវរៀបចំចងក្រងសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ស្របតាមមាតិកាដែលបានកំណត់។

**៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍**

• មេឃុំ ចៅសង្កាត់ត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ដោយ ៖

បង្ហាញក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ស្នើសុំឱ្យអ្នកចូលរួមផ្តល់យោបល់ទៅលើក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន

• គ.ផ.ថ និងស្មៀនឃុំ សង្កាត់បូកសរុបយោបល់ដែលទទួលបានពិនិត្យពិចារណា និងកែសម្រួលសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន។

**៦ ការពិនិត្យ និងការផ្តល់យោបល់**

គ.ផ.ថ ដាក់ជូនមេឃុំ ចៅសង្កាត់នូវសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដែលបានកែសម្រួលទៅតាមយោបល់ ដែលទទួលបានពីកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យ និងផ្តល់យោបល់។

មេឃុំ ចៅសង្កាត់ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដែលបានកែសម្រួល ។

គ.ផ.ថ កែសម្រួលសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ទៅតាមមតិយោបល់របស់មេឃុំ ចៅសង្កាត់ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត។

**ជំហានទី៣ ៖ ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

**៦ ការអនុម័តផែនការអភិវឌ្ឍន៍**

**កិច្ចប្រជុំក្រុមប្រឹក្សា**

- បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ គ.ផ.ថ កែសម្រួលសៀវភៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទៅ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**ការពិនិត្យអនុលោមភាព**

មេឃុំ ចៅសង្កាត់ចាត់ចែងបញ្ជូនសៀវភៅផែនការអភិវឌ្ឍន៍ដែលអនុម័តរួចដើម្បីពិនិត្យ និងផ្តល់អនុលោមភាពដូចខាងក្រោម ៖

+ ឃុំ ៖ អភិបាលខេត្ត

+ សង្កាត់ក្នុងក្រុង ៖ អភិបាលក្រុង

+ សង្កាត់ក្នុងរាជធានី ៖ អភិបាលរាជធានី។ អភិបាលរាជធានី ខេត្ត ឬក្រុងត្រូវពិនិត្យ និងផ្តល់អនុលោមភាពក្នុងរយៈពេល៤៥ ថ្ងៃ បន្ទាប់ពីទទួលបានពីឃុំ សង្កាត់។ ក្នុងរយៈពេល៤៥ថ្ងៃ នេះបើគ្មានការឆ្លើយតបទេនោះត្រូវបានចាត់ទុកថា អភិបាលរាជធានី ខេត្ត ឬក្រុងបានឯកភាពទៅលើសេចក្តីព្រាងស្តីពីផែនការអភិវឌ្ឍឃុំ សង្កាត់។

គ.ផ.ថ និងស្មៀនពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ទៅតាម មតិយោបល់របស់អភិបាលរាជធានី ខេត្ត ឬ ក្រុង។ ក្នុងករណីមានការកែសម្រួល មេឃុំ ចៅសង្កាត់ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័តនូវចំណុចដែលកែសម្រួលទាំងនោះ។

**ការដាក់ចេញសេចក្តីសម្រេច**

បន្ទាប់ពីទទួលបានអនុលោមភាព និងអនុម័តទៅលើចំណុច គ.ផ.ថ ត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ។

**៦ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍**

មេឃុំ ចៅសង្កាត់ត្រូវរៀបចំបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ផ្សព្វផ្សាយជាសាធារណៈ និងតម្កល់ទុកនៅ ៖

- រដ្ឋបាលឃុំ សង្កាត់

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ

- រដ្ឋបាលរាជធានី ខេត្ត

- មន្ទីរផែនការរាជធានី ខេត្ត

- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

មេឃុំ ចៅសង្កាត់ត្រូវណែនាំឱ្យមានការផ្សព្វផ្សាយខ្លឹមសារផែនការ អភិវឌ្ឍន៍ឃុំ សង្កាត់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធដូចជា ផ្សព្វផ្សាយក្នុងកិច្ចប្រជុំនានាក្នុងវេទិកាសាធារណៈតាមសារព័ត៌មាន វិទ្យុ និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន។

## ២.១០ ដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ មាន៣ជំហាន គឺ ៖

ជំហានទី១ ៖ ការប្រមូលព័ត៌មានស្ដីពីតម្រូវការរបស់មូលដ្ឋាន សម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ជំហានទី២ ៖ ការរៀបចំសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ជំហានទី៣ ៖ ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធី វិនិយោគបីឆ្នាំរំកិល

**ជំហានទី១៖ ការប្រមូលព័ត៌មានស្ដីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

**➢ ប្រជុំនៅឃុំ សង្កាត់លើកទី១**

គ.ជ.ថ ជួបប្រជុំដើម្បីពិនិត្យ និងវិភាគស្ថានភាពទូទៅនៅក្នុងឃុំ សង្កាត់។ ក្រៅពី គ.ជ.ថ អ្នកចូលរួមផ្សេងៗទៀតរួមមាន ស្មៀន មេភូមិ ឬតំណាងភូមិ ជនបង្គោល ក្រុមការងារគណនេយ្យភាពសង្គម (បើមាន) ក្រុមយុវជន តំណាងការិយាល័យជំនាញ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានាតាមការស្ម័គ្រចិត្ត

គ.ជ.ថ រៀបចំតារាងបញ្ហា តម្រូវការ និងដំណោះស្រាយ ។

មេភូមិនីមួយៗស្រង់យកបញ្ហា តម្រូវការ និងដំណោះស្រាយ ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន។

**➢ ប្រជុំនៅតាមភូមិ**

មេភូមិត្រូវរៀបចំប្រជុំភូមិ ដើម្បីបង្ហាញ និងពិគ្រោះយោបល់អំពី បញ្ហា តម្រូវការ និងដំណោះស្រាយជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន។ ចំពោះសង្កាត់ក្នុងករណីពិបាកប្រមូលប្រជាពលរដ្ឋមកប្រជុំមេភូមិអាចប្រមូលបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋតាមមធ្យោបាយដូចខាងក្រោម ៖

- ចុះជួបប្រជាពលរដ្ឋផ្ទាល់តាមខ្នងផ្ទះ និង ឬ

- ផ្ញើទម្រង់តារាងកំណត់បញ្ហាតម្រូវការដល់គ្រួសារនីមួយៗឱ្យបំពេញ និងកំណត់កាលបរិច្ឆេទដែលមេភូមិត្រូវប្រមូលត្រឡប់មកវិញ។

**➢ប្រជុំនៅឃុំ សង្កាត់លើកទី២**

- ផ្អែកតាមលទ្ធផលនៃការប្រជុំភូមិ គ.ផ.ថ បូកសរុប ផ្ទៀងផ្ទាត់ និងកែសម្រួលតារាងបញ្ហាតម្រូវការ និងដំណោះស្រាយដែលជាលទ្ធផលនៃការប្រជុំនៅឃុំ សង្កាត់លើកទី១

- គ.ផ.ថ បំប្លែងបញ្ហាតម្រូវការ និងដំណោះស្រាយទាំងនោះ ទៅជាគម្រោងសកម្មភាព និងចាត់អាទិភាពគម្រោងសកម្មភាពទាំងនេះ

- គ.ផ.ថ ពិចារណា និងកំណត់សកម្មភាពនានានៃការអនុវត្តមុខងារជា កាតព្វកិច្ចដែលរដ្ឋបាលឃុំ សង្កាត់ទទួលបាន និងឬគម្រោងនានាដែលត្រូវប្រើប្រាស់មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ

- គ.ផ.ផ ក៏ត្រូវពិចារណា និងកំណត់គម្រោងជាអាទិភាពដែលសល់ ពីឆ្នាំកន្លងទៅផងដែរ

- គ.ផ.ថ ស្រង់សកម្មភាព គម្រោងទាំងនេះចូលតារាង "**តម្រូវការគម្រោង សកម្មភាពអាទិភាព**" តាមផ្នែក និងតាមលំដាប់លំដោយអាទិភាពផ្អែកតាមការណែនាំរបស់ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ គ.ផ.ថ ត្រូវរៀបចំទម្រង់ទី១របស់ក្រុង ស្រុក ខណ្ឌ ចំពោះគម្រោងទាំងឡាយណាដែលរដ្ឋបាលឃុំ សង្កាត់ត្រូវស្នើសុំបញ្ចូលក្នុងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ ហើយផ្ញើទម្រង់ទី១នេះ ទៅក្រុង ស្រុក ខណ្ឌតាមកាលបរិច្ឆេទកំណត់។

**ជំហានទី២ ៖ ការរៀបចំសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**

**➢ ការពិនិត្យគម្រោង និងសកម្មភាពអាទិភាពឡើងវិញ**

បន្ទាប់ពីកិច្ចប្រជុំផ្សព្វផ្សាយនៅថ្នាក់ក្រុងស្រុកខណ្ឌ គ.ផ.ថ ត្រូវពិនិត្យមើលឡើងវិញនូវតម្រូវការគម្រោងសកម្មភាពអាទិភាពរបស់ឃុំ សង្កាត់ដែលបានរៀបចំក្នុងជំហានទី១ ដើម្បី ៖

- កំណត់យកគម្រោងសកម្មភាពណាដែលនៅតែមានតម្រូវការ ជាអាទិភាព

- ដកចេញនូវគម្រោងសកម្មភាពណាដែលលែងមានតម្រូវការ ចាំបាច់។

**➢ ការត្រៀមរៀបចំចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ**

បន្ទាប់ពីទទួលបានព័ត៌មានអំពីលទ្ធភាពថវិកា គ.ផ.ថ ពិនិត្យ និងសម្រេចជាបណ្ដោះអាសន្នក្នុងការជ្រើសរើសគម្រោង សកម្មភាព អាទិភាពសម្រាប់ប្រើប្រាស់ថវិកានេះដោយជ្រើសរើស ៖

- គម្រោង ឬសកម្មភាពសម្រាប់ប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ ដោយផ្អែកតាមអាទិភាពនៃសំណើគម្រោងក្នុងផ្នែកនីមួយៗ

- គម្រោង ឬសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារជាកាតព្វកិច្ច

- គម្រោងអាទិភាពនានាសម្រាប់ប្រើប្រាស់មូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

បន្ទាប់មក គផ.ថ រៀបចំតារាង "**តម្រូវការគម្រោង សកម្ម ភាពអាទិភាព**" ដោយបំពេញបន្ថែមនូវប្រភព

ថវិកា។ បន្ទាប់ពីរៀបចំតារាង រួច គ.ផ.ថ រៀបចំតារាងលទ្ធផលនៃការអនុវត្តគម្រោងក្នុងឆ្នាំថវិកា។

មេឃុំ ចៅសង្កាត់ផ្ញើតារាងទៅមន្ទីរផែនការរាជធានី ខេត្ត តាមរយៈរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំឯកសារសម្រាប់សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

➢ **ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ក្រុង ស្រុក ខណ្ឌ**

មេឃុំ ចៅសង្កាត់ចាត់ចែងសម្រាប់ការចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ក្រុងស្រុក ខណ្ឌ ដូចខាងក្រោម ៖

- ចាត់តំណាងប្រតិភូចូលរួម ៖ មេឃុំ ចៅសង្កាត់ ស្មៀន សមាជិក ក្រុមប្រឹក្សា១-២រូប និងមេភូមិមួយចំនួនតាមការចាំបាច់

- រៀបចំឯកសារបិទបង្ហាញ ៖ ផែនទីភូមិសាស្ត្រ សេដ្ឋកិច្ច ចាត់តំណាង០១រូបចាំបំភ្លឺខ្លឹមសារតារាងនានាដែលបានបិទបង្ហាញក្នុងសិក្ខាសាលា

ត្រៀមឯកសារសម្រាប់កិច្ចព្រមព្រៀងបណ្ដោះអាសន្ន។ តំណាងប្រតិភូ០១រូប(ធម្មតាគឺមេឃុំចៅសង្កាត់)ឡើងបង្ហាញបំភ្លឺខ្លឹមសារអត្ថន័យដើម្បីសុំការគាំទ្រថវិកា និងបច្ចេកទេស។

➢ **ការងារក្រោយពីសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ក្រុង ស្រុក ខណ្ឌ**

គ.ផ.ថ ពិនិត្យ និងកែសម្រួលផ្អែកតាមលទ្ធផលសិក្ខាសាលាសមាហរណកម្ម ព្រមទាំងឯកភាពគ្នាក្នុងការប្រើប្រាស់មូលនិធិរបស់ឃុំ សង្កាត់(បើមានការផ្លាស់ប្តូរ)សម្រាប់អនុវត្តគម្រោងសកម្មភាពអាទិភាពដែលគ្មានការសន្យាគាំទ្រ។

មេភូមិនីមួយៗត្រូវស្រង់យកឈ្មោះគម្រោងសកម្មភាពដែលស្ថិតនៅក្នុងភូមិរបស់ខ្លួនដើម្បីយកទៅបង្ហាញ និងពិភាក្សាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងភូមិខ្លួន។ មេភូមិបូកសរុបមតិយោបល់ហើយដាក់ជូន គ.ផ.ថ ពិនិត្យពិចារណា និងកែតម្រូវ

➢ **ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ**

គ.ផ.ថ រៀបចំតារាងតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់។

➢ **ការចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

គ.ផ.ថ រៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ស្របតាមមាតិកាដែលបានកំណត់។

## ជំហានទី៣៖ ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

**៦ កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគ**

បន្ទាប់ពីទទួលបានសេចក្តីព្រាងកម្មវិធីវិនិយោគ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគ។

បន្ទាប់ពីកិច្ចប្រជុំក្រុមប្រឹក្សា គ.ជ.ថ ត្រូវ ៖

- កែតម្រូវកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ទៅតាមការសម្រេច របស់ក្រុមប្រឹក្សាឃុំ សង្កាត់

- តាក់តែងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

-ដាក់ជូនប្រធានក្រុមប្រឹក្សាឃុំ សង្កាត់នូវសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលបានកែតម្រូវរួច និងសេចក្តីព្រាងសេចក្តីសម្រេចដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគនេះដើម្បីពិនិត្យ និងចុះហត្ថលេខា។

**៦ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគ**

**ការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគ ៖** មេឃុំ ចៅសង្កាត់ត្រូវរៀបចំបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគ**

សៀវភៅកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវតម្កល់ទុកនៅ ៖សាលាឃុំ សង្កាត់ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ឬការិយាល័យផែនការ និងអភិវឌ្ឍទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត មន្ទីរផែនការរាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

មេឃុំ ចៅសង្កាត់ត្រូវណែនាំឱ្យមានការផ្សព្វផ្សាយខ្លឹមសារ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំសង្កាត់ និងអ្នកពាក់ព័ន្ធ ដូចជាផ្សព្វផ្សាយ ក្នុងកិច្ចប្រជុំនានា ក្នុងវេទិកាសាធារណៈតាមសារព័ត៌មាន វិទ្យុ និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន

មេឃុំ ចៅសង្កាត់ត្រូវរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគម្រោងប្រើប្រាស់មូលនិធិឃុំ សង្កាត់ ស្រុក ក្រុង ខណ្ឌ រាជធានី ខេត្ត និងគម្រោងប្រើប្រាស់ប្រភពមូលនិធិផ្សេងទៀតដែលត្រូវអនុវត្តក្នុងដែនដីរដ្ឋបាលឃុំ សង្កាត់ដើម្បីឱ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់បានដឹង។

## ២.១១ ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ

### ២.១១.១ និយមន័យភូមិ

ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន។ ភូមិជាច្រើនរួមផ្តុំគ្នាបង្កើតបានឃុំ ឬសង្កាត់មួយ។ ភូមិមិនមែនជាថ្នាក់រដ្ឋបាលដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ។[8]

[8] ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ទំព័រ៦៦

ភូមិនីមួយៗត្រូវគ្រប់គ្រងដោយមេភូមិម្នាក់អមដោយអនុប្រធានភូមិម្នាក់ និងសមាជិកភូមិម្នាក់ជាជំនួយការ។

**២.១១.២ បែបបទ និងនីតិវិធីនៃការជ្រើសរើសមេភូមិ**

អនុលោមតាមមាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសមេភូមិម្នាក់សម្រាប់ភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ខ្លួន។

**២.១១.២.១ ភូមិដែលត្រូវជ្រើសរើសមេភូមិ**

ការរៀបចំជ្រើសរើសមេភូមិត្រូវធ្វើឡើងតែនៅភូមិណាដែលក្រសួង មហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ។

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់របស់ខ្លួនធ្វើសេចក្តីរាយការណ៍អំពីឈ្មោះភូមិដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ។

**២.១១.២.២ លក្ខណៈសម្បត្តិនៃបេក្ខជនមេភូមិ**

បេក្ខជនមេភូមិ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននោះ យ៉ាងតិច ៦ខែជាប់ៗគ្នា។

**២.១១.២.៣ នីតិវិធីជ្រើសរើសមេភូមិ**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការជ្រើសរើសមេភូមិសម្រាប់ភូមិនីមួយៗ តាមនីតិវិធីដូចខាងក្រោម ៖

- ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់
- ការជ្រើសរើសបេក្ខជនមេភូមិ
- ការពិនិត្យបេក្ខជនមេភូមិ និងការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ
- កិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិ
- សេចក្តីសម្រេចតែងតាំងមេភូមិ។

**ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**

មុននឹងដំណើរការជ្រើសរើសមេភូមិ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ កោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដែលមានរបៀបវារៈដូចតទៅ ៖

- រាយការណ៍អំពីភូមិដែលទទួលស្គាល់ដោយក្រសួងមហាផ្ទៃ

- ណែនាំអំពីនីតិវិធីដាក់ស្នើបេក្ខជនមេភូមិ
- កាលវិភាគនៃដំណើរការជ្រើសរើសមេភូមិ

មេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អំពីឈ្មោះភូមិដែលក្រសួងមហាផ្ទៃទទួលស្គាល់។

អធិបតីអង្គប្រជុំត្រូវណែនាំដល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងអំពីនីតិវិធីនៃការដាក់ស្នើបេក្ខជនមេភូមិ។

អង្គប្រជុំ ក៏ត្រូវឯកភាពគ្នាផងដែរទៅលើកាលវិភាគនៃដំណើរការ ជ្រើសរើសមេភូមិ ដូចតទៅ ៖

- កាលបរិច្ឆេទនៃការដាក់ស្នើបេក្ខជនមេភូមិ
- កាលបរិច្ឆេទនៃការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យបេក្ខជន មេភូមិ និងបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ
- កាលបរិច្ឆេទនៃការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីបោះឆ្នោត ជ្រើសរើសមេភូមិ។

**ការជ្រើសរើសបេក្ខជនមេភូមិ**

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងរបស់ខ្លួនរៀបចំជ្រើសរើសបេក្ខជនមេភូមិយ៉ាងតិច ០៣រូប សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។

មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅ សង្កាត់រងទី២ម្នាក់ៗ ត្រូវជ្រើសរើសបេក្ខជនមេភូមិយ៉ាងតិចចំនួន ០១រូប ក្នុងមួយភូមិដែលមានលក្ខណៈសម្បត្តិដូចចំណុច **២.១១.២.២** និងដែលខ្លួនទុកចិត្តនៅគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់របស់ខ្លួន។

ប្រសិនបើ ក្នុងចំណោមមេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ មានអ្នកណាម្នាក់មិនដាក់ស្នើបេក្ខជន មេភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ ៖

- ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសមេភូមិបើបេក្ខជនមេភូមិ ដែលបានស្នើមានចំនួនយ៉ាងតិច ០៣រូប សម្រាប់មួយភូមិ។
- ស្នើឱ្យមេឃុំ ចៅសង្កាត់ ឬជំទប់ទី១ ចៅសង្កាត់រងទី១ ឬជំទប់ទី២ ចៅសង្កាត់រងទី២ណាដែលបានដាក់ស្នើបេក្ខជនមេភូមិរួចហើយដាក់ស្នើបេក្ខជនមេភូមិបន្ថែម ដើម្បីឱ្យចំនួនបេក្ខជនមេភូមិសម្រាប់មួយភូមិមានចំនួនយ៉ាងតិច ០៣ រូប ប្រសិនបើបេក្ខជនមេភូមិដែលបានស្នើមានចំនួនតិចជាង ០៣រូប សម្រាប់មួយភូមិ។

មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងត្រូវពិគ្រោះពិភាក្សាគ្នាខិតខំជ្រើសរើសឱ្យមានស្ត្រីសម្រាប់ជាបេក្ខជនមេភូមិនៅគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់របស់ខ្លួន។

បន្ទាប់ពី ជ្រើសរើសបានបេក្ខជនហើយ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរស្នើសុំដាក់បេក្ខជនមេភូមិទាំងនោះរៀងៗខ្លួនទៅប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីរៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេបរបស់បេក្ខជនមេភូមិ។

**ការពិនិត្យបេក្ខជនមេភូមិ និងការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ**

បន្ទាប់ពី ទទួលបានសំណើសុំដាក់បេក្ខជនមេភូមិពីមេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ប្រធានក្រុម ប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បី ៖

- ពិនិត្យបេក្ខជនមេភូមិ និង
- រៀបចំអនុម័តបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការពិនិត្យបេក្ខជនមេភូមិដែលបានដាក់ស្នើដោយមេឃុំ ចៅសង្កាត់និងជំទប់ចៅសង្កាត់រងម្តងមួយភូមិៗ ថាតើបេក្ខជនមេភូមិទាំងនោះមានលក្ខណសម្បត្តិសមស្របដូចបានកំណត់ដែរទេ។

គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិមានសមាសភាព ០៣រូប ដូចខាងក្រោម ៖

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់០១រូប ជាប្រធាន
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់០១រូប ជាសមាជិក
- ស្មៀនឃុំ សង្កាត់ ជាសមាជិក

គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ មានភារកិច្ច ៖

- រៀបចំសន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗនៃភូមិទាំងអស់នៅក្នុងឃុំ សង្កាត់
- រៀបចំ និងអនុវត្តកិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិគ្រប់ភូមិទាំងអស់នៅក្នុងឃុំ សង្កាត់

សន្លឹកឆ្នោតនៃភូមិនីមួយៗត្រូវ ៖

- ប្រើក្រដាសពណ៌សដែលមានទម្រង់ ទំហំដូចគ្នាដោយសរសេរ ឈ្មោះបេក្ខជន ទៅតាមលំដាប់អក្សរនៃឈ្មោះរបស់បេក្ខជន (សរសេរដោយដៃ ឬ ម៉ាស៊ីនអង្គលីលេខ ឬ កុំព្យូទ័រ)
- រៀបចំឱ្យមានចំនួនស្មើនឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- មានត្រារបស់ឃុំ សង្កាត់ ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោត។

**កិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិ**

បន្ទាប់ពីបានរៀបចំសន្លឹកឆ្នោតតាមភូមិនីមួយៗគ្រប់ភូមិទាំងអស់ក្នុងឃុំ សង្កាត់របស់ខ្លួន រួចហើយគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិត្រូវដាក់សន្លឹកឆ្នោតទាំងនោះជូនមេឃុំ ចៅសង្កាត់ពិនិត្យ។

ក្រោយពីពិនិត្យឃើញថា សន្លឹកឆ្នោតទាំងនោះមានភាពត្រឹមត្រូវហើយ មេឃុំ ចៅសង្កាត់ដែលជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីរៀបចំការបោះឆ្នោតក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីថ្ងៃដាក់ស្នើបេក្ខជននោះ។

មុននឹងដំណើរការបោះឆ្នោតជ្រើសរើសមេភូមិ អធិបតីនៃអង្គប្រជុំ ដែលជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជម្រាបជូនអង្គប្រជុំអំពីគោលការណ៍ សំខាន់ៗដូចខាងក្រោម ៖

- សន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ សន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យដូចៗគ្នានូវទម្រង់ ទំហំ និងឈ្មោះបេក្ខជន។
- សមាជិកក្រុមប្រឹក្សាម្នាក់ៗ មានសិទ្ធិទទួលបានសន្លឹកឆ្នោតមួយ សន្លឹកសម្រាប់ភូមិមួយ ដែលបានចែកជូនក្នុងពេលបោះឆ្នោត។
- សមាជិកក្រុមប្រឹក្សាម្នាក់ត្រូវគូសជ្រើសយកបេក្ខជនដែលខ្លួន គាំទ្រតែម្នាក់ប៉ុណ្ណោះលើសន្លឹកឆ្នោតដែលបានចែកជូនដោយ គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ។

សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែល ៖

- មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូនដោយគណៈកម្មការ បោះឆ្នោតជ្រើសរើសមេភូមិ
- គ្មានត្រារបស់ឃុំ សង្កាត់
- គូសគាំទ្របេក្ខជនលើសពីម្នាក់
- មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
- មានសញ្ញាដែលធ្វើឱ្យគេស្គាល់អ្នកបោះឆ្នោត
- រហែក ឬខូច
- មានគំនូសតែគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសមេភូមិមិនអាចកំណត់បានថាគាំទ្របេក្ខជនណាមួយ។

បន្ទាប់ពីណែនាំរួចហើយ អធិបតីនៃអង្គប្រជុំត្រូវប្រគល់កម្មវិធីជូន គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិដើម្បីរៀបចំបោះឆ្នោតម្តងមួយភូមិៗ។

ប្រធានគណៈកម្មការបោះឆ្នោតត្រូវ ៖

- ជម្រាបជូនអង្គប្រជុំថា “ ការបោះឆ្នោតនេះគឺជាការបោះឆ្នោតសម្ងាត់ ”
- បង្ហាញ និងណែនាំអំពីលក្ខណៈនៃសន្លឹកឆ្នោត ៖
    - ខាងមុខមានសរសេរអក្សរថា“**សន្លឹកឆ្នោត** ”

◦ ខាងក្នុងមានបញ្ជីឈ្មោះបេក្ខជនមេភូមិ

◦ ខាងក្រោយមានត្រាឃុំ សង្កាត់

ណែនាំអំពីរបៀបគូសសន្លឹកឆ្នោត ៖ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគូសសញ្ញា «✓» នៅលើសន្លឹកឆ្នោតត្រង់ប្រអប់ “ការបោះឆ្នោតគាំទ្រ ” នៅជួរបន្ទាត់នៃឈ្មោះបេក្ខជនមេភូមិ តែម្នាក់ប៉ុណ្ណោះដែលខ្លួនគាំទ្រ។

- បន្ទាប់ពីគូសសន្លឹកឆ្នោតរួចត្រូវយកមកដាក់ក្នុងហិបឆ្នោត។

បោះគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិអនុវត្តដំណើរការឆ្នោត ម្តងមួយភូមិៗដូចតទៅ ៖

- ប្រធានគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ អានឈ្មោះ បេក្ខជនមេភូមិជូនអង្គប្រជុំ

- ចែកសន្លឹកឆ្នោតជូនសមាជិកក្រុមប្រឹក្សាដែលមានវត្តមានក្នុងកិច្ច ប្រជុំម្នាក់មួយសន្លឹកដើម្បីបោះឆ្នោតជ្រើសរើសមេភូមិ។

- ទុកពេលវេលាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការបោះឆ្នោត និងដាក់សន្លឹកឆ្នោតដែលបានគូសរួចទៅក្នុងហិបឆ្នោត។

- យកសន្លឹកឆ្នោតចេញពីហិបឆ្នោត បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់បានដាក់សន្លឹកឆ្នោតរបស់ខ្លួនទៅក្នុងហិបឆ្នោតគ្រប់ៗគ្នា។

- រាប់សន្លឹកឆ្នោតដែលបានបោះហើយនៅចំពោះមុខអង្គប្រជុំ។

- ពិនិត្យសន្លឹកឆ្នោត និងកត់ត្រាលទ្ធផលនៃការបោះឆ្នោតដោយធ្វើការបែងចែកការងារក្នុងគណៈកម្មការដូចខាងក្រោម ៖

- ប្រធានគណៈកម្មការពិនិត្យសន្លឹកឆ្នោត អានឈ្មោះបេក្ខជនមេភូមិដែលបានទទួលការបោះឆ្នោតគាំទ្រ និងបង្ហាញសន្លឹកឆ្នោតនោះដល់អង្គប្រជុំ។

- សមាជិកគណៈកម្មការដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់កត់ត្រាលទ្ធផលនៃ ការបោះឆ្នោតលើក្តារខៀន ឬក្រដាសផ្ទាំងធំ

- សមាជិកគណៈកម្មការដែលជាស្មៀនឃុំ សង្កាត់ធ្វើកំណត់ហេតុ។

បន្ទាប់មកប្រធានគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិត្រូវរាយការណ៍ជូនអង្គប្រជុំដូចខាងក្រោម៖

+ សន្លឹកឆ្នោតដែលបានបោះសរុបចំនួន ........សន្លឹក

+ សន្លឹកឆ្នោតបានការចំនួន ........សន្លឹក

+សន្លឹកឆ្នោតមិនបានការចំនួន ........សន្លឹក

លទ្ធផលមានដូចតទៅ ៖

+ លោក ឬលោកស្រី................បាន...........សំឡេង

+ លោក ឬលោកស្រី................បាន...........សំឡេង

+ លោក ឬលោកស្រី................បាន...........សំឡេង

**បញ្ជាក់** ៖ សមាជិកគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវបោះឆ្នោតជ្រើសរើសមេភូមិដូចសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដទៃទៀតដែរ។

អធិបតីនៃអង្គប្រជុំត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតបន្ទាប់ពីការរាប់សន្លឹកឆ្នោតហើយភ្លាម។

បន្ទាប់មក អធិបតីនៃអង្គប្រជុំត្រូវចាត់ឱ្យគណៈកម្មការបោះឆ្នោតរៀបចំបោះឆ្នោតជ្រើសរើសមេភូមិផ្សេងទៀតដែលនៅសល់ជាបន្តបន្ទាប់ហូតគ្រប់ចំនួនភូមិដែលបានទទួលស្គាល់ជាផ្លូវការ។

បេក្ខជនដែលជាប់ឆ្នោត គឺជាបេក្ខជនដែលមានសំឡេងឆ្នោតគាំទ្រច្រើនជាងគេហើយសំឡេងគាំទ្រនោះត្រូវមានចំនួនលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ក្នុងករណីដែលមានបេក្ខជនណាដែលមានសំឡេងឆ្នោតស្មើគ្នា ៖

- បើបេក្ខជនដែលមានសំឡេងស្មើគ្នានោះ សុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រីសំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

- បើបេក្ខជនដែលមានសំឡេងស្មើគ្នានោះម្នាក់ជាបុរស និងម្នាក់ជាស្ត្រី បេក្ខជនស្ត្រីត្រូវបានជាប់ឆ្នោតជាមេភូមិ។

ចំពោះបេក្ខជនភូមិណាដែលមិនបានទទួលសំឡេងគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល អង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ដាក់ស្នើបេក្ខជនជាថ្មី និងដំណើរការបោះឆ្នោតជាថ្មីសម្រាប់ភូមិនោះទៅតាមបែបបទនីតិវិធីដូចបានរៀបរាប់ខាងលើ។ ក្នុងករណីនេះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំដើម្បីបោះឆ្នោតជ្រើសរើសបេក្ខជនមេភូមិនោះជាលើកទី២ ក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោតលើកទី១។

នៅក្នុងការបោះឆ្នោតលើកទី២នេះ ប្រសិនបើ បេក្ខជននៅតែមិនបានទទួលសំឡេងគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូលទៀតអង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ជ្រើសយកតែបេក្ខជន០២រូបដែលមានសំឡេងឆ្នោតគាំទ្របន្តបន្ទាប់គ្នាមកធ្វើការបោះឆ្នោតជ្រើសរើសសារឡើងវិញភ្លាម។

បន្ទាប់ពីជ្រើសរើសបានបេក្ខជន០២រូបដែលមានសំឡេងឆ្នោតគាំទ្របន្តបន្ទាប់គ្នារួចមកគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិត្រូវរៀបចំសន្លឹកឆ្នោត និងអនុវត្តដំណើរការបោះឆ្នោតដូចដំណើរ ការបោះឆ្នោតលើកទី១ និងលើកទី២ដែរ។

ក្នុងការបោះឆ្នោតសាឡើងវិញភ្លាមនេះបើនៅតែមិនមានបេក្ខជនណាម្នាក់ដែលបានទទួលសំឡេងគាំទ្រលើសពីពាក់កណ្តាលនៃសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសម្រេចជ្រើសរើសនៅក្នុងអង្គប្រជុំ ៖

- សម្រេចជ្រើសយកបេក្ខជនជាស្ត្រីធ្វើជាមេភូមិបើក្នុងចំណោមបេក្ខជនទាំងពីរខាងលើនេះមានម្នាក់ជាស្ត្រី

- សម្រេចជ្រើសយកបេក្ខជនដែលមានអាយុចាស់ជាងធ្វើជាមេភូមិបើបេក្ខជនទាំងពីរខាងលើនេះសុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រី។

**សេចក្តីសម្រេចតែងតាំងមេភូមិ**

បន្ទាប់ពី ក្រុមប្រឹក្សាឃុំ សង្កាត់បោះឆ្នោតជ្រើសរើសបានមេភូមិរួចរាល់ហើយមេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចតែងតាំងមេភូមិទាំងនោះក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោតគាំទ្រ។

## ២.១២ ការតែងតាំងជំនួយការមេភូមិ

មេឃុំ ចៅសង្កាត់ត្រូវណែនាំមេភូមិនីមួយៗដែលបានទទួលការតែងតាំងជាផ្លូវការរួចហើយនោះឱ្យជ្រើសរើសបេក្ខជនជំនួយការរបស់ខ្លួនជាអនុប្រធាន និងសមាជិកភូមិរួចហើយលើកសំណើដល់មេឃុំចៅ សង្កាត់សាមីដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនពិនិត្យ និងអនុម័តក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃ បន្ទាប់ពីថ្ងៃតែងតាំងមេភូមិនោះជាផ្លូវការ។

ការជ្រើសរើសជំនួយការមេភូមិសម្រាប់ភូមិនីមួយៗ ត្រូវអនុវត្តតាម នីតិវិធីដូចខាងក្រោម ៖

- ការប្រជុំជាមួយមេភូមិដែលទើបតែងតាំងថ្មី
- ការជ្រើសរើសបេក្ខជនជំនួយការមេភូមិ
- ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត
- សេចក្តីសម្រេចតែងតាំង។

**ការប្រជុំជាមួយមេភូមិដែលទើបតែងតាំងថ្មី**

បន្ទាប់ពីការតែងតាំងមេភូមិរួច មេឃុំ ចៅសង្កាត់ត្រូវរៀបចំការប្រជុំមួយជាមួយនឹងមេភូមិដែលទើបនឹងតែងតាំងថ្មីទាំងនោះដើម្បី ៖

- ណែនាំអំពីនីតិវិធីនៃការដាក់ស្នើបេក្ខជនជំនួយការមេភូមិ
- កំណត់កាលបរិច្ឆេទដាក់សំណើបេក្ខជនជំនួយការមេភូមិ។

**ការជ្រើសរើសបេក្ខជនជំនួយការមេភូមិ**

មេភូមិនីមួយៗដែលបានទទួលការតែងតាំងជាផ្លូវការរួចហើយត្រូវ ធ្វើការជ្រើសរើសបេក្ខជនជំនួយការរបស់ខ្លួន ជាអនុប្រធាន និង សមាជិកភូមិ ក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃបន្ទាប់ពីថ្ងៃតែងតាំងមេភូមិនោះជាផ្លូវការ។

លក្ខណៈសម្បត្តិនៃបេក្ខជនជំនួយការមេភូមិ មានដូចតទៅ ៖

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួន កំពុងរស់នៅ
- មានអាយុយ៉ាងតិច២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននោះ យ៉ាងតិច០៦ខែជាប់ៗគ្នា។

**ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងអនុម័តបេក្ខជនអនុប្រធានភូមិ និងសមាជិកភូមិនៃភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ខ្លួនម្តងមួយភូមិៗក្នុងរយៈពេល៥ថ្ងៃ បន្ទាប់ពីទទួលសំណើដាក់បេក្ខជនពីមេភូមិ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តដោយលើកដៃលើបេក្ខជនអនុប្រធានភូមិ និងសមាជិកភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ខ្លួនតាមសំឡេងភាគច្រើនលើសពីពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងមូល។

បើបេក្ខជនសម្រាប់មុខតំណែងជាអនុប្រធានភូមិ និងសមាជិកភូមិនៃភូមិណាមួយមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ដោយសំឡេងភាគច្រើនលើសពី ពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលទេនោះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់របស់ខ្លួនពិគ្រោះពិភាក្សា ជាមួយជំទប់ចៅសង្កាត់រងដើម្បីណែនាំមេភូមិឱ្យដាក់ស្នើបេក្ខជនជាលើកទី២ក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ។

ក្នុងករណីនេះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំដើម្បីពិនិត្យ និង អនុម័តទៅលើបេក្ខជនជំនួយការនោះជាលើកទី២ ក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ស្នើបេក្ខភាព។

លើកទី២នេះប្រសិនបើបេក្ខជនដែលបានដាក់ស្នើនេះនៅតែមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ដោយសំឡេងភាគច្រើនលើសពី ពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលទេនោះ អធិបតីអង្គប្រជុំត្រូវស្នើឱ្យអង្គប្រជុំសម្រាកក្នុងរយៈពេលខ្លីមួយប្រហែល៣០នាទីដើម្បីឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានពេលវេលា សម្រាប់គិតពិចារណា និងពិគ្រោះយោបល់គ្នា។ បន្ទាប់មកអធិបតីអង្គប្រជុំត្រូវចាត់ឱ្យរៀបចំអនុម័ត ជាថ្មីម្តងទៀត ដោយសំឡេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានចូលរួមប្រជុំ។

**សេចក្តីសម្រេចតែងតាំងជំនួយការមេភូមិ**

បេក្ខជនជំនួយការមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តយល់ព្រមរួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចតែងតាំងជំនួយការមេភូមិនីមួយៗ ក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័ត។

**៦ អាណត្តិការងាររបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ**

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែងត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិក ភូមិថ្មីមកជំនួស។

# ជំពូកទី៣
# គុណសម្បត្តិ និងគុណវិបត្តិ

# ជំពូកទី ៣

## ៣.១ គុណសម្បត្តិ

បើសិនជារដ្ឋមិនប្រមូលផ្តុំអំណាចរដ្ឋបាលតែម្នាក់ឯងហើយទទួលស្គាល់ឱ្យសមូហភាពផ្សេងទៀតមានអំណាចរដ្ឋបាលសម្រេចដោយស្វ័យភាពនូវរាល់កិច្ចការផងទាំងពួងដែលជាផលប្រយោជន៍ទូទៅរបស់ប្រជាជននៅក្នុងសមូហភាពនោះផ្ទាល់របៀបគ្រប់គ្រងនេះ គេហៅថា របៀប “ វិមជ្ឈការរដ្ឋបាលដែនដី ” ។ គេអាចហៅបានម្យ៉ាងទៀតថា “ រដ្ឋបាលវិមជ្ឈការ ” ដែលមានលក្ខណៈវិនិច្ឆ័យ ដូចតទៅនេះ ៖

- **អំណាចរាស្ត្រ សម្រាប់ផលប្រយោជន៍រាស្ត្រ**
  - **ផលប្រយោជន៍រាស្ត្រ**

គេត្រូវធ្វើការវែកញែករវាងផលប្រយោជន៍រាស្ត្រទូទាំងប្រទេស និងផលប្រយោជន៍រាស្ត្រតាមទីកន្លែង។

ផលប្រយោជន៍រាស្ត្រទូទាំងប្រទេស គឺជាផលប្រយោជន៍ជាតិដែលរដ្ឋមានតួនាទីជាអ្នកការពារយ៉ាងមុតមាំបំផុត។ ហើយគ្មានផលប្រយោជន៍ណាមួយអាចមានឧត្តមភាពលើផលប្រយោជន៍ជាតិបានឡើយនៅក្នុងប្រទេសនីមួយៗ ។

ផលប្រយោជន៍រាស្ត្រតាមទីកន្លែងដូចជា តាមភូមិឃុំ សង្កាត់ជាដើមជាផលប្រយោជន៍ផ្ទាល់សម្រាប់រាស្ត្រនៅទីកន្លែងនោះក្នុងជីវភាពរស់នៅរាល់ថ្ងៃរបស់រាស្ត្រ។ ប្រជាជន តែងតែប្រកបមុខរបរខ្លះមានផ្ទះសំបែងផ្ទាល់ខ្លួនខ្លះ ជួលផ្ទះគេនៅ ធ្វើដំណើរចុះឡើង រៀន សូត្រ កំសាន្ត និងធ្វើបុណ្យទាន។ល។ នៅនឹងទីកន្លែង ឬភូមិកំណើតរបស់ខ្លួន។ បញ្ហាដែលកើតឡើងនៅនឹងទីកន្លែង សម្រាប់ដោះស្រាយជីវិតការរស់នៅជាមួយគ្នាក្នុងសង្គមតូចៗកំរិតនេះក៏មានសារសំខាន់ណាស់ដែរសម្រាប់ជនទាំងនោះ។ ការអភិវឌ្ឍន៍តាមភូមិឃុំ សង្កាត់មានភាពជាក់ស្តែង ស្រណុកមើលឃើញ និងទាញយកផលដោយផ្ទាល់ៗបានដោយប្រជាជនដែលនៅក្នុងភូមិ ឬឃុំសង្កាត់នោះ ។

ដូច្នេះយើងឃើញថា មានផលប្រយោជន៍ផ្ទាល់របស់រាស្ត្រនៅតាមទីកន្លែងដែលផ្សេងពីផលប្រយោជន៍ជាតិទូទៅ។ ផលប្រយោជន៍រាស្ត្រតាមទីកន្លែង ពុំអាចនឹងគ្រប់គ្រងបានឱ្យពិតប្រាកដដោយរដ្ឋទេ ទោះបីក្នុងរបបវិសហមជ្ឈការក៏ដោយ ពីព្រោះរាស្ត្រពុំមែនជាម្ចាស់អ្នកដោះស្រាយបញ្ហាដោយផ្ទាល់។ អ្វីៗសុទ្ធតែមន្ត្រីដែលតំណាងឱ្យអំណាចកណ្តាលជាអ្នកសម្រេចឱ្យទាំងអស់ មិនដូចរាស្ត្រខ្លួនឯងដែលស្គាល់បញ្ហាដោះស្រាយដោយខ្លួនឯងឡើយ។

នៅក្នុងសង្គមដែលកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដហើយដែលមានអ្នកចេះដឹងច្រើនគេតែងទទួលស្គាល់ឱ្យមានការគ្រប់គ្រងផលប្រយោជន៍រាស្ត្រតាមទីកន្លែង ដោយរាស្ត្រខ្លួនឯង ។

- **អំណាចរាស្ត្រ**

រាស្ត្រគ្រប់គ្រងផលប្រយោជន៍ខ្លួនតាមទីកន្លែង គឺតាមរយៈតំណាងដែលរាស្ត្របោះឆ្នោតជ្រើសតាំង តាមលក្ខណៈលទ្ធិប្រជាធិបតេយ្យ។ រដ្ឋត្រូវធ្វើច្បាប់បោះឆ្នោមួយសម្រាប់ជ្រើសរើសអង្គការដឹកនាំនៃសមូហភាពវិមជ្ឈការ។ ធម្មតាគេច្រើនឃើញមានក្រុមប្រឹក្សា( ឬសភា ) មួយ និងប្រធានក្រុមប្រឹក្សា (ឬ ប្រធានសភា ) មួយ។ ក្រុមប្រឹក្សាមានអំណាចបញ្ញត្តិ ( អំណាចបញ្ជា ) រីឯប្រធានមាន អំណាចប្រតិបត្តិ ប៉ុន្តែអំណាចនេះប្រើបានតែក្នុងព្រំដែននៃមណ្ឌលរដ្ឋបាលវិមជ្ឈការប៉ុណ្ណោះ ។ អំណាចចេញពីរាស្ត្រទាំងអស់។ នៅក្នុងប្រទេសសេរីជឿនលឿន គេប្រើលទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ ( ឬពាក់កណ្តាល ដោយផ្ទាល់)ដោយមានវិធានការបណ្តេញចោលមុនចប់អាណត្តិ នូវអ្នកតំណាងណាដែលធ្វើខុស ដែលមិនបានបំពេញតួនាទីខ្លួនឱ្យបានដូចពាក្យសន្យាក្នុងពេលបោះឆ្នោត។ ការបណ្តេញនេះត្រូវមានចែងក្នុងច្បាប់ គ្រប់គ្រងរដ្ឋបាលវិមជ្ឈការ។ អាណត្តិ របស់អ្នកតំណាង ច្រើនមានរយៈពេលមធ្យមពី ៥ ទៅ ៦ ឆ្នាំ ដើម្បីឱ្យមានពេលធ្វើ និងអនុវត្តផែនការអភិវឌ្ឍន៍ ។

❖ **អំណាចសម្រេចស្វយ័ត**

អង្គការវិមជ្ឈការ ដែលរាស្ត្របានបោះឆ្នោតជ្រើសរើស មានអំណាចសម្រេចស្វយ័តលើគ្រប់បញ្ហា និងជីវភាពរស់នៅរបស់ប្រជាជនដូចជាបញ្ហាសង្គមកិច្ច សេដ្ឋកិច្ច ហិរញ្ញវត្ថុ វប្បធម៌ រដ្ឋបាលហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍ជាដើម។ អង្គការអំណាចកណ្តាល ឬអំណាចវិសហមជ្ឈការពុំមានសិទ្ធិអំណាចអ្វីមកបញ្ជា ឬក៏ដាក់លក្ខខណ្ឌអ្វីបន្តិចបន្តួចសោះឡើយក្នុងការសម្រេចរបស់អង្គការវិមជ្ឈការ។ អង្គការអំណាចកណ្តាល ឬ អំណាចវិសហមជ្ឈការ មានអំណាចបានត្រឹមតែធ្វើការត្រួតពិនិត្យរដ្ឋបាល ( contrôle administrative ) ដែលគេច្រើននិយមហៅថា “ អំណាចអាណាព្យាបាល ” ( pouvoir de tùtelle )។

❖ **អំណាចត្រួតពិនិត្យរដ្ឋបាលរបស់រដ្ឋ**

រដ្ឋ គឺជាអំណាចកណ្តាលមិនអាចត្រួតពិនិត្យអ្វីបានទាំងអស់លើអំណាចវិមជ្ឈការបើគ្មាន អត្ថបទច្បាប់ (សភា) ចែងច្បាស់លាស់។ ក្នុងករណីមានច្បាប់ចែងច្បាស់លាស់រដ្ឋមិនអាចធ្វើការត្រួតពិនិត្យឱ្យហួសពីអ្វីដែលមានចែងក្នុងអត្ថបទច្បាប់នោះ ។

ច្បាប់(សភា) អាចកំណត់ទំហំធំ ឬតូចនៃការត្រួតពិនិត្យរបស់រដ្ឋទៅតាមគោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាលដោយលទ្ធភាពយ៉ាងទូលាយ។ ប៉ុន្តែគេមិនត្រូវឱ្យមានការត្រួតពិនិត្យស្មើនឹងការត្រួតពិនិត្យរបស់អំណាចនាយចៅហ្វាយឡើយ ពីព្រោះបើពុំដូច្នោះទេវាអស់មានអំណាចវិមជ្ឈការហើយ ។

តាមធម្មតា ការត្រួតពិនិត្យអាណាព្យាបាល អាចធ្វើលើបុគ្គលនៃអាជ្ញាធរវិមជ្ឈការ ឬលើសេចក្តីសម្រេច ឬលើមធ្យោបាយនៃការអនុវត្តសេចក្តីសម្រេចរបស់អាជ្ញាធរវិមជ្ឈការ ។

- **ការត្រួតពិនិត្យលើបុគ្គល**

នៅប្រទេសបារាំងដែលមានទម្លាប់មជ្ឈការ តាំងពីយូរណាស់មកហើយរដ្ឋរក្សាអំណាចខ្លះរបស់ខ្លួនសម្រាប់ដាក់ទណ្ឌកម្មវិន័យជាបណ្ដោះអាសន្នដូចជាការព្យួរការងារ (មេឃុំ) « មែរ » ឬជាស្ថាពរដូចជាការបណ្ដេញ « មែរ » ឬរំសាយក្រុមប្រឹក្សា (ឃុំ)« ម៉ុយនីស៊ីប៉ាល់ » (Conseil municipal) ជាដើម។ យើងគិតទៅ ឃើញដូចជាមិន " ប្រជាធិបតេយ្យ " សោះ ពីព្រោះ « មែរ » និង « ក្រុមប្រឹក្សា (ឃុំ) » សុទ្ធតែជ្រើសតាំងដោយការបោះឆ្នោតជាសកល។ នេះជាស្នាមនៃមជ្ឈការនិយមជំនាន់ដើម ដែលនៅសេសសល់ មិនទាន់រលុបអស់។ ប៉ុន្តែ អំណាចរដ្ឋបាលនេះ ប្រើបានដោយពិបាក ពីព្រោះច្បាប់គេដាក់លក្ខខណ្ឌយ៉ាងតឹងតែង។ រឿងរំសាយក្រុមប្រឹក្សា (ឃុំ) ជារឿងធំណាស់ ពីព្រោះ គេត្រូវធ្វើដោយ " ដេក្រក្នុងក្រុមប្រឹក្សារដ្ឋមន្ត្រី " (décret en Conseil des Ministres) ដែលប្រធានាធិបតីជាអ្នកចុះហត្ថលេខា និងជាអ្នកអធិបតីក្នុងអង្គប្រជុំធំនៃគណៈរដ្ឋមន្ត្រី ដែលបានសម្រេចរឿងនេះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិត្រឹមលើកសំណើប៉ុណ្ណោះ។ ដូច្នេះដើម្បីរំសាយក្រុមប្រឹក្សា(ឃុំ) និង« មែរ » ដែលរាស្ត្រក្នុង(ឃុំ)បានរើសដោយវិធីបោះឆ្នោត គេត្រូវឱ្យប្រមុខរដ្ឋដែលរាស្ត្រទូទាំងប្រទេសបានបោះឆ្នោតជ្រើសរើស ធ្វើជាអាជ្ញាកណ្ដាល ដោយមិនអនុញ្ញាតឱ្យរដ្ឋាភិបាលសម្រេចផ្ទាល់តែម្ដងបានឡើយ។ បន្ថែមពីលើនេះគេមានវិធានការ សម្រាប់ធ្វើការបោះឆ្នោតរើសក្រុមប្រឹក្សា(ឃុំ) « ម៉ុយនិស៊ីប៉ាល់ » ថ្មីឡើងវិញឱ្យបានឆាប់រហ័សបំផុត ដើម្បីការពារការរំលោភអំណាច ពីរដ្ឋ។

នៅប្រទេសកម្ពុជា « ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ » បានចែងក្នុងមាត្រា ៥៨ ថា : ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់នោះជាបន្ទាន់ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នោះឡើងវិញទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ »

មតិខ្លះយល់ថា មាត្រា ៥៨ នេះអាចធ្វើឱ្យលោយរបបវិមជ្ឈការទៅវិញដោយមកពីហេតុថា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតែម្នាក់ឯងជាអ្នកត្រួតពិនិត្យផងហើយជាអ្នកសម្រេចរំសាយផងដោយគ្រាន់តែនិយាយថា « ផ្ទុយនឹងនយោបាយរដ្ឋាភិបាលមួយម៉ាត់ប៉ុណ្ណោះ » ។

មតិខ្លះយល់ថាក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិប្ដឹងទៅនាយករដ្ឋមន្ត្រី និងប្ដឹងទៅតុលាការបានចំពោះការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបើទោះបីជាច្បាប់មិនបានចែងប្រាប់ឱ្យច្បាស់ពីព្រោះឃុំ សង្កាត់ជានីតិបុគ្គលសាធារណៈ ។

មតិខ្លះយល់ថា មាត្រា៥៨ ខុសនឹងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពីព្រោះរដ្ឋមន្ត្រីអាចរំសាយអង្គការទាំងមូលដែលជ្រើសរើសឡើងដោយរាស្ត្របោះឆ្នោតដោយហេតុផលនយោបាយប៉ុណ្ណោះ ។

អ្វីៗនៅមិនទាន់ដំណើរការនៅឡើយយើងគួររង់ចាំមើលការជាក់ស្តែងដែលនឹងចេញមកពីការអនុវត្តច្បាប់នេះ ។

❖ **ការត្រួតពិនិត្យលើសេចក្តីសម្រេច**

ការត្រួតពិនិត្យស្រេចតែច្បាប់កំណត់ការត្រួតពិនិត្យលើសេចក្តីសម្រេចរបស់អង្គការវិមជ្ឈការអាចធ្វើលើនីត្យានុកូលភាព ឬលើកាលានុវត្តភាព (opportunité) ឬទាំងពីរមុខនេះក៏បាន។

អាជ្ញាធរដែលមានអំណាចអាណាព្យាបាល អាចមានសិទ្ធិ តាមច្បាប់ចែង ៖

• ឱ្យទិដ្ឋាការយល់ព្រមជាមុន លើសេចក្តីសម្រេចរបស់អង្គការវិមជ្ឈការ ទើបសេចក្តីសម្រេចនោះយកទៅអនុវត្តបាន។ ក្នុងករណីនេះ អំណាចវិមជ្ឈការសឹងតែអស់ន័យ។

• ឬលុបចោលសេចក្តីសម្រេចរបស់អង្គការវិមជ្ឈការ ជាបច្ឆាកាល ដោយមូលហេតុផ្សេងៗដែលមានចែងក្នុងច្បាប់ ។

• ឬលុបចោលសេចក្តីសម្រេចរបស់អង្គការវិមជ្ឈការ តែក្នុងករណីមានអនីត្យានុកូលភាព(illégalité)។

• ឬប្រើអំណាចធ្វើជំនួស (pouvoir de substitution) អង្គការវិមជ្ឈការក្នុងករណីដែលអាជ្ញាធរវិមជ្ឈការមិនព្រមអនុវត្តកាតព្វកិច្ចស្របច្បាប់ ឬ មិនចេះវិធានច្បាប់ហិរញ្ញវត្ថុសាធារណៈដើម្បីធ្វើថវិការបស់ខ្លួន។ល។

សេចក្តីសម្រេចរបស់អាជ្ញាធរអាណាព្យាបាល ជាសេចក្តីសម្រេចរដ្ឋបាល ដែលអាជ្ញាធរវិមជ្ឈការអាចប្តឹង អំពីការរំលោភអំណាច ឬការរំលោភច្បាប់ ឬការខុសនឹងច្បាប់ ទៅតុលាការរដ្ឋបាល បានជានិច្ច។

❖ **បុគ្គលភាពគតិយុត្ត**

ផលប្រយោជន៍រាស្ត្រតាមទីកន្លែងអាចនឹងគ្រប់គ្រងនៅបានក្នុងរង្វង់ដែនដីមួយជាសមូហភាព។ គេហៅថា“សមូហភាពដែនដី”(collectivité territoriale) ឬ “ សមូហភាពតាមទីកន្លែង ”(collectivité locale) ។

ច្បាប់(សភា)ទុក “ សមូហភាពដែនដី ” ឬ “ សមូហភាពតាមទីកន្លែង ” ជានីតិបុគ្គលសាធារណៈ ។ ក្នុងឋានៈជានីតិបុគ្គលសាធារណៈសមូហភាពនេះមានបុគ្គលភាពគតិយុត្តគឺថាមានអំណាចសម្រេចស្វយ័តមានទ្រព្យសម្បត្តិផ្ទាល់ មានធនធាន និងមូលធនផ្ទាល់ មានថវិកាផ្ទាល់ មានសិទ្ធិធ្វើពាណិជ្ជកម្ម ឧស្សាហកម្ម មានសិទ្ធិប្តឹងទៅតុលាការ ។ល។

ដូចតែនីតិបុគ្គលឯទៀតៗដែរ ។ តើសមូហភាពនេះមានសិទ្ធិខ្ចីបុលប្រាក់ ដើម្បីយកមកធ្វើការអភិវឌ្ឍតាមទីកន្លែងឬទេ? ជាគោលការណ៍ គឺត្រូវតែមានសិទ្ធិនេះ។ អង្គការដែលមានសិទ្ធិសម្រេច គឺអង្គការវិមជ្ឈការដែលរាស្ត្របាន

បោះឆ្នោតជ្រើសរើសនោះដូចជាក្រុម ប្រឹក្សាឃុំ ជាដើម។ ពីព្រោះអ្វី ? ពីព្រោះ បើខ្វះសិទ្ធិនេះ សមូហភាពវិមជ្ឈការនឹងមិនមែនជានីតិបុគ្គលពេញលក្ខណៈឡើយ ។

រដ្ឋ ជានីតិបុគ្គលសាធារណៈ មានសិទ្ធិខ្ចីប្រាក់ពីគេ ឬឱ្យប្រាក់គេខ្ចី តាមការអនុញ្ញាតពីរដ្ឋសភា។ ក្នុងរបបវិមជ្ឈការពិតប្រាកដ ក្រុមប្រឹក្សាឃុំត្រូវមានអំណាចប្រហាក់ប្រហែលនឹងរដ្ឋសភាដែរប៉ុន្តែនៅថ្នាក់ឃុំ។ មាត្រា២ នៃព្រះរាជក្រមស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចែងថា : “ ឃុំសង្កាត់ជានីតិបុគ្គល ” ប៉ុន្តែ មាត្រា៨០ មិនឱ្យ ឃុំ សង្កាត់មានសិទ្ធិខ្ចីប្រាក់។ ដូច្នេះ ឃុំ សង្កាត់នៅកម្ពុជាកើតចេញមក ជា នីតិបុគ្គលមិនគ្រប់លក្ខណៈ។ ប៉ុន្តែ នយោបាយវិមជ្ឈការនៅកម្ពុជា ត្រូវធ្វើឡើង ទៅតាមដំណាក់កាលដោយសន្សឹមៗសិន ទម្រាំនឹងមានបទពិសោធន៍គ្រប់គ្រាន់ ដើម្បីអាចបោះមួយជំហានទៅមុខទៀត ។

❖ **មណ្ឌលរដ្ឋបាលវិមជ្ឈការ**

ធម្មតាគេច្រើនយកមណ្ឌលរដ្ឋបាលវិសហមជ្ឈការទុកជាមណ្ឌលរដ្ឋបាលវិមជ្ឈការដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។

ឧទាហរណ៍ ៖ ដូចជាឃុំសង្កាត់ជាដើម ។ កាលសម័យសង្គម រាស្ត្រនិយម (១៩៥៥-១៩៦៩) មណ្ឌលរដ្ឋបាលវិមជ្ឈការមាន ក្រុង ខេត្ត និង សង្កាត់(ឃុំ )។

ដូច្នេះវិមជ្ឈការពិតប្រាកដប្រកបដោយអំណាចសម្រេចស្វយ័តជាក់ស្តែង នាំឱ្យមានការអភិវឌ្ឍរីកចម្រើនក្នុងជីវភាពរស់នៅរបស់ប្រជាជននាំឱ្យរាស្ត្រមានការចូលរួមក្នុងការសម្រេចអ្វីៗដែលជាប្រយោជន៍របស់ខ្លួន ហើយនឹងនាំឱ្យរាស្ត្រមានរបៀបគ្រប់គ្រងរដ្ឋបាល ដែលរាស្ត្រខ្លួនឯងស្គាល់ច្បាស់តាមទីកន្លែង។

## ៣.២ គុណវិបត្តិ

គេអាចរាប់គុណវិបត្តិបានបីយ៉ាងសំខាន់ៗ គឺ :

- អំណាចកណ្តាលអាចខ្សោយ ពីព្រោះ រដ្ឋលែងម្ចាស់ការ ក្តាប់ស្ថានការណ៍មិនបានអស់។
- វិមជ្ឈការនាំឱ្យមានការសម្រេចផ្សេងៗគ្នាតាមទីកន្លែងនូវតម្លៃសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងនឹងត្រូវខុសគ្នាចំពោះប្រភេទដូចគ្នាដែលជាហេតុនាំឱ្យមានការ មិនស្មើភាពគ្នាខ្លះពីទីកន្លែងមួយទៅទីកន្លែងមួយ។ នៅប្រទេសបារាំង តម្លៃលតាប័ត្ររថយន្ត ខុសគ្នាពីខេត្តមួយទៅខេត្តមួយ។ សារពើពន្ធខុសគ្នាពី “ កុម្មីន ” (ឃុំ) មួយទៅ“ កុម្មីន ” មួយ ។ អ្នកនៅ “ កុម្មីន ” ធំ ជួនកាលទៅជាបង់សារពើពន្ធតិចជាង “ កុម្មីន ”តូច ទៅវិញ ។ ដូច្នេះ បើគិតមកកម្ពុជាវិញ កន្លែងខ្លះ វាអាចធ្វើ ឱ្យអ្នកក្រកាន់តែក្រទៅ ក៏មិនដឹង? ពីព្រោះ ឃុំ សង្កាត់តូច មនុស្សតិច ច្រើនកំណត់តម្លៃសារពើពន្ធនិងសេវាខ្ពស់ជាងឃុំ សង្កាត់ធំ ដែលមាន ប្រជាជនច្រើន។ ឧបមាថា ចំណាយក្នុងការសាងសង់ផ្លូវតូចមួយអស់១០លានរៀល។ ឃុំ " ក " មាន ៥០០ គ្រួសារ និងឃុំ" ខ "១០០០គ្រួសារ។

បន្ទុកសាធារណៈក្នុងការធ្វើផ្លូវនេះគេត្រូវយកមកចែកនឹងចំនួនគ្រួសារ។ ដូច្នេះ ក្នុងឆ្នាំដែលត្រូវសាងសង់ផ្លូវនោះ គ្រួសារនីមួយៗក្នុងឃុំ " ក " ត្រូវបង់ ២០.០០០រៀល ចំណែកឯក្នុងឃុំ " ខ " គ្រួសារនីមួយៗ ត្រូវបង់តែ ១០.០០០ រៀល ។

• ផែនការរដ្ឋក្នុងការអភិវឌ្ឍ អាចជួបនឹងបញ្ហាអនាធិបតេយ្យ នៃគម្រោងអភិវឌ្ឍន៍ ផ្សេងៗរបស់ឃុំសង្កាត់ បើសិនជាមិនមានវិធានការទប់ស្កាត់ ជាមុន ។[9]

[9] នីតិរដ្ឋបាលទូទៅ បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០១២ ទំព័រ ៣៩៣-៤០១

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការអនុវត្តតាមបែបវិមជ្ឈការនៅថ្នាក់ ឃុំ សង្កាត់ គឺ ជាកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ មានគោលបំណងផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានជាពិសេសក្រុមដែលតំណាងឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងក្រុមជនងាយរងគ្រោះនានាអាចមានសិទ្ធិចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋានឱ្យមានប្រសិទ្ធភាព តម្លាភាពតាមរយៈការលើកកម្ពស់នូវភាពងាយស្រួលក្នុងការទទួលបាននូវព័ត៌មាន និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការពិនិត្យតាមដានលើការងារ ថវិកា និងការបំពេញការងាររបស់រដ្ឋបាលនៅមូលដ្ឋាន ហើយវាក៏ជាដំណើរការ នៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និង រដ្ឋបាលថ្នាក់មូលដ្ឋានផងដែរ។ លើសពីនេះទៅទៀត វាក៏ជាមធ្យោបាយមួយដែលផ្សារភ្ជាប់គ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ច ដែលក្នុងនោះរាល់ការធ្វើសេចក្តីសម្រេចចិត្តអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលឃុំ សង្កាត់ត្រូវបានប្រកាន់យកតាមកិច្ចដំណើរតាមបែបប្រជាធិបតេយ្យ ហើយជាទូទៅ កិច្ចដំណើរការនេះរួមមានរាល់សកម្មភាពទាំងឡាយណាដែលផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួនអាចការពារនូវផលប្រយោជន៍របស់ខ្លួន និងពិនិត្យតាមដានលើការបំពេញការងាររបស់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និងអ្នកផ្តល់សេវាកម្មនានាដែលជាអ្នកអនុវត្តសេចក្តីសម្រេចចិត្តទាំងឡាយពាក់ព័ន្ធសិទ្ធិ និងធនធានហើយការផ្តល់សេវាកម្មនៅមូលដ្ឋានគឺត្រូវតែសមស្របទៅតាមតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនជាពិសេសការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់តាមបែបវិមជ្ឈការ គឺជាការរៀបចំនូវយន្តការនានានៃការប្រាស្រ័យទាក់ទងគ្នាដ៏ច្បាស់លាស់ និងមានប្រសិទ្ធភាពរវាងតួអង្គចំនួនពីរក្រុមពោលគឺ ក្រុមប្រជាពលរដ្ឋ និងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវមានការឆ្លើយតបនិងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

ឆ្លងតាមរយៈការស្រាវជ្រាវនូវ ប្រធានបទខាងលើរបស់ក្រុមយើងខ្ញុំរួចមកសបញ្ជាក់ឱ្យឃើញថាការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការពិតជាបានផ្តល់នូវសារៈប្រយោជន៍ជូនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានផ្ទាល់ ព្រមទាំងមន្ត្រីរាជការដែលបម្រើការនៅក្នុងថ្នាក់មូលដ្ឋានធ្វើឱ្យការបំពេញការងារទទួលបាននូវប្រសិទ្ធិភាព តម្លាភាពផ្តល់ផលប្រយោជន៍ជូនទៅដល់សង្គមជាតិទាំងមូល រួមទាំងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលស្ថិតនៅតាមភូមិ ឃុំ សង្កាត់ជាដើម ជាផលប្រយោជន៍ផ្ទាល់សម្រាប់រាស្ត្រក្នុងជីវភាពរស់នៅរួមទាំងជួយសម្រួលដល់ថវិកា ពេលវេលា និងមធ្យោបាយធ្វើដំណើរក្នុងការស្វែងរកការផ្តល់សេវាសាធារណៈដែលនៅជិតបំផុត និងស្ថិតនៅក្នុងថ្នាក់មូលដ្ឋានដែលពួកគេរស់នៅផ្ទាល់ ម្យ៉ាងវិញទៀតការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ នេះក៏បានចូលរួមផ្តល់អំណាចជូនដល់រាស្ត្រក្នុងការជ្រើសរើសតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដែលពួកគេស្រឡាញ់ទុកចិត្ត និងស្គាល់ច្បាស់ ។

ដូចនេះ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការពិតប្រាកដប្រកបដោយអំណាចសម្រេចស្វយ័តជាក់ស្តែងនាំឱ្យមានការអភិវឌ្ឍរីកចម្រើនក្នុងជីវភាពរបស់ប្រជាពលរដ្ឋ នាំឱ្យរាស្ត្រមានការចូលរួមសម្រេចអ្វីដែលជាផលប្រយោជន៍របស់ខ្លួនហើយ និង នាំឱ្យរាស្ត្រមានរបៀបគ្រប់គ្រងរដ្ឋបាលដែលខ្លួនឯងស្គាល់ច្បាស់តាមទីកន្លែង ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះរួចមក យើងឃើញថាឃុំសង្កាត់គឺជាអង្គការតំណាងអោយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំសង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំសង្កាត់ មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលក្រុមប្រឹក្សាឃុំសង្កាត់ថ្មីចូលកាន់មុខតំណែង។

ដើម្បីធានាការគ្រប់គ្រងការងាររដ្ឋបាលឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព តម្លាភាព នៅក្នុងមូលដ្ឋាននោះត្រូវមានការចូលរួមចំណែកពីៈ

មន្ត្រី ៖ ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង បំពេញតួនាទីភារកិច្ចប្រកបដោយភាពទំនួលខុសត្រូវ តម្លាភាព សមភាព គុណធម៌ មិនស៊ីសំណូកសូកប៉ាន់ប្រកាន់បក្សពួកនិយម។

ប្រជាពលរដ្ឋ ៖ ត្រូវមានការចូលរួមស្វែងយល់ ឯកភាព ក្នុងការអនុវត្ត និងគោរពនូវ បទប្បញ្ញត្តិ បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តនានា របស់ឃុំ សង្កាត់នោះ។

រដ្ឋ ៖ ត្រូវផ្តល់ធនធានមនុស្សនិងធនធានហិរញ្ញវត្ថុពីថ្នាក់ជាតិ ទៅដល់ឃុំ សង្កាត់អោយមានភាពសមស្របក្នុងគោលបំណងធ្វើអោយឃុំ សង្កាត់មានការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងនាមយើងជានិស្សិតផ្នែករដ្ឋបាលសាធារណៈ យើងខ្ញុំមានអនុសាសន៍សម្រាប់ធ្វើការស្នើសុំ ក៏ដូចជាសំណូមពរ ដូចខាងក្រោមៈ

- ជំរុញអោយមានវេទិកាសាធារណៈដើម្បីអោយប្រជាពលរដ្ឋបានលើកឡើងនូវតម្រូវការ និងបញ្ហាដែលពួកគាត់កំពុងជួបប្រទះ ដើម្បី រិះរកវិធានការដោះស្រាយជូនពួកគាត់
- ជួយដោះស្រាយបញ្ហាដល់ប្រជាជនអោយបានរហ័ស និងភាពទទួលខុសត្រូវខ្ពស់
- បង្កើនការដោះស្រាយវិវាទជូនប្រជាពលរដ្ឋ នៅពេលមានវិវាទ
- ពង្រឹង និងបង្កើនសមត្ថភាពរបស់មន្ត្រីនៅក្នុងរដ្ឋបាលឃុំ សង្កាត់ដើម្បីអោយការបំពេញការងារតួនាទីប្រកបដោយប្រសិទ្ធភាព ។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ (រៀបតាមឋានុក្រម)

➢ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នស/រកម/០៣០១/០៥១៩ មីនា ២០០១

➢ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នស/រកម/០៣០១/០៤២៧ មិថុនា ២០០៦

➢ព្រះរាជក្រឹត្យចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ១៩០៨

➢ព្រះរាជក្រម លេខ៤០នស ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៤៣

➢ព្រះរាជក្រម លេខ៣៤០នស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៥៩

➢ព្រះរាជក្រឹត្យ លេខ៣៨៣/៦៩CE/ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ១៩៦៩

➢អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់លេខ ១៦ អនក្របក, ២៥ កុម្ភៈ ២០០២

➢អនុក្រឹត្យស្តីពីការផ្ទេរិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់លេខ ២២ អនក្របក២៥ មីនា ២០០២។

➢អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់, លេខ២៦អនក្រ.បកដ, ០២ មេសា ២០០២

➢ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩១៩

## ២. សៀវភៅតែងនិពន្ធ

➢សៀវភៅ **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ** របស់ក្រសួងមហាផ្ទៃបោះពុម្ព ខែកក្កដា ឆ្នាំ ២០១៧

➢**រដ្ឋបាលទូទៅ បណ្ឌិត សាយ បូរី** បោះពុម្ពលើកទី៤ ទំព័រ ៣៩៣-៤០១

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នស/រកម/០៣០១/០៥១៩ មីនា ២០០១

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែមរិមជ្ឈការ

**ឧបសម្ព័ន្ធរូបភាព៖** កម្រងរូបភាពនិស្សិត និង សាស្ត្រចារ្យណែនាំ

# ឧបសម្ព័ន្ធទី១ ៖ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :៕.

# ច្បាប់

# ស្ដីពី

# ការគ្រប់គ្រងរដ្ឋបាល

# ឃុំ សង្កាត់

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៚.

សិរបេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។៚

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

មាត្រា ១៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

មាត្រា ១៦.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ៚

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។៚

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

**មាត្រា ២២.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើស ពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិង កំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃ អង្គប្រជុំមានឧត្តមានុភាព ។

**មាត្រា ២៣.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជា- ធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើ នេះ ។

**មាត្រា ២៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំ ក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុម ប្រឹក្សាឃុំ សង្កាត់បានឡើយ ។៚

## ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្ដល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំតាក់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។ល។

**មាត្រា ៣២.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.-**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្អែកតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងបាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្ដាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤
## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចិរភាព សំរាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ ៘.

មាត្រា ៤៣.-

ក្នុងតួនាទីចំពីកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

មាត្រា ៤៤.-

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

មាត្រា ៤៥.-

រដ្ឋបាលឃុំ សង្កាត់ពុំមានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ

- ប្រៃសណីយ៍និងទូរគមនាគមន៍

- ការពារប្រទេស ។ល។

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសិរុះសិរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។ល។

**មាត្រា ៤៩.-**

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងវង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៥១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យ ពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៚.

**មាត្រា ៥២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- វាយតំលៃប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចវិមជ្ឈការអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

**មាត្រា ៥៤.-**

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្ត ឬបទបញ្ជាផ្ទៃក្នុងនិងវិន័យឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំលាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ៥៨.-**

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥៩.-**

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

**មាត្រា ៦០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦១.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

**មាត្រា ៦២.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ល.ក.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ម.ភ.

**មាត្រា ៦៥.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតំរូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក

- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ។ល។

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។ ៸ .

**មាត្រា ៧៤.-**

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៧៥.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមាន:

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៦.-**

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។៚.

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំ-ណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យ។ បានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន : ឥ.ត.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទ័ណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។ល។

ក្នុងករណីបានអនុវត្តរូបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តរូបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។៚.

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិធានការគោលនយោបាយសំរាប់ផ្តល់ពត៌មាននិងតំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល។

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៧នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។/.

រាជធានីភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង យូ ហុកគ្រី

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ០៣ ឆ្នាំ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

**ឆាវី ធាវី**

# ឧបសម្ព័ន្ធទី២ ៖ អនុក្រឹត្យស្តីពីការ ធ្វើវិមជ្ឈការអំណាចតួនាទី និង ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់តាមបែបវិមជ្ឈការ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរសិទ្ធិទីមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃ ទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃ ទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២ ។
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

### សំរេច

## ជំពូកទី១

## ការប្រគល់អំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអភិបាលកិច្ចរបស់ឃុំ សង្កាត់

មាត្រា ១.-

ឃុំ សង្កាត់ជានីតិបុគ្គល ។

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាឃុំ សង្កាត់មួយ ។

ឃុំ សង្កាត់មានមុខងារ អំណាច និងករណីយកិច្ចក្នុងការគ្រប់គ្រង និង ធ្វើអភិបាលកិច្ចក្នុងឃុំ សង្កាត់របស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាជាធរមាន។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសតាំងឡើង ដោយការបោះឆ្នោតស្របតាមល័កខ័ណ្ឌនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋទាំងអស់នៅក្នុង ឃុំ សង្កាត់របស់ខ្លួន។

មាត្រា ២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់លិខិតជាលាយល័ក្ខអក្សរដល់ក្រសួងមហាផ្ទៃ និង ចម្លងជូនអភិបាលខេត្ត ក្រុងនីមួយៗនូវ ÷

- បញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយដែលបានជាប់ឆ្នោតជាផ្លូវការតាមឃុំ សង្កាត់នីមួយៗ
- ឈ្មោះរបស់បេក្ខជនដែលត្រូវបានប្រកាសថាជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- ឈ្មោះរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅ សង្កាត់រងទី១ និង ជំទប់ទី២ ចៅសង្កាត់រងទី២ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសចេញពីបញ្ជីឈ្មោះបេក្ខជនដែលបានជាប់ឆ្នោតជាផ្លូវការ
- ឈ្មោះសមាជិកថ្មីដើម្បីជំនួសសមាជិកនៃក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែងក្នុងករណីដែលមានសមាជិកណាម្នាក់នៃក្រុមប្រឹក្សាឃុំ សង្កាត់បានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែង ។

មាត្រា ៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវរៀបចំឱ្យមានកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១៤ថ្ងៃ យ៉ាងយូរបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

បែបបទ នីតិវិធី និង កិច្ចដំណើការនៃការប្រជុំលើកដំបូងនេះត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។



ĸ

**មាត្រា ៤.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការថា " ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ " ។

មេឃុំមានងារជាផ្លូវការថា "មេឃុំ" និង ចៅសង្កាត់មានងារជាផ្លូវការថា "ចៅសង្កាត់ " ។

ជំទប់មានងារជាផ្លូវការថា "ជំទប់" និង ចៅសង្កាត់រង មានងារជាផ្លូវការថា "ចៅសង្កាត់រង " ។

សមាជិកដែលបានជាប់ឆ្នោត ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានងារជាផ្លូវការថា " សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ " ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងមានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួនកាន់តំណែងនោះប៉ុណ្ណោះ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួននៅជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប៉ុណ្ណោះ ។

**មាត្រា ៥.-**

ឃុំ សង្កាត់នីមួយៗត្រូវមានស្មៀនឃុំ សង្កាត់មួយរូប ។

ស្មៀនឃុំ សង្កាត់ត្រូវបានតែងតាំង និងត្រូវបានប្រើប្រាស់ក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ។

ស្មៀនឃុំ សង្កាត់ត្រូវជួយ និង ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោមទៅតាមតួនាទី និងមុខងារដែលបានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុមតបទបញ្ជាផ្ទៃក្នុងសំរាប់ដំណើរការ និង ចាត់ចែងកិច្ចប្រជុំព្រមទាំងអនុវត្តការកិច្ចរបស់ខ្លួន ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំផ្អែកលើមូលដ្ឋាននៃសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៧.-**

សាលាឃុំ សង្កាត់ គឺជាការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជាទីចាត់ការរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

សាលាឃុំ សង្កាត់ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការប្រចាំថ្ងៃស្របតាមម៉ោងធ្វើការរបស់ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

ក្នុងកំឡុងពេលម៉ោងធ្វើការប្រជាពលរដ្ឋមានសិទ្ធិ ÷

- ធ្វើទំនាក់ទំនង និង ធ្វើកិច្ចការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ទទួលពត៌មានអំពីសំណើ និង ការងារនានាពីក្រុមប្រឹក្សាឃុំ សង្កាត់

- មើល និង អានឯកសាររបស់ឃុំ សង្កាត់

- ចូលរួមយោបល់ ឬ តវ៉ាលើបញ្ហាណាមួយ ។

**មាត្រា ៨.–**

ឃុំ សង្កាត់គឺជាម្ចាស់លើលិខិត និង ឯកសារទាំងអស់ដែលបានប្រគល់ត្រឹមត្រូវដល់ ÷

- ការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

- គណៈកម្មាធិការណាមួយរបស់មេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬមន្ត្រីនៅការិយាល័យក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៩.–**

ឃុំ សង្កាត់គឺជាម្ចាស់លើរាល់លិខិត និង ឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សា ឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និង ជាម្ចាស់កម្មសិទ្ធិលើតែមប្រ៊ី ត្រាឃុំ សង្កាត់ ព្រមទាំងឧបករណ៍ផ្សេងៗ ទៀតទាំងអស់របស់ឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម តែមប្រ៊ី ត្រា អោយបានត្រឹមត្រូវ និង គង់វង្ស ។

**មាត្រា ១០.–**

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវរៀបចំឱ្យមានក្ដារខៀនពត៌មានសាធារណៈនៅសាលាឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសកន្លែងដែលសមស្របដើម្បីដាក់ក្ដារខៀនពត៌មានសាធារណៈនៅតាមភូមិ ។

ទីកន្លែងដែលដាក់ក្ដារខៀនពត៌មានសាធារណៈត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ប្រសិនបើកន្លែងនោះមានអ្នកកាន់កាប់រួចហើយ ។

ក្ដារខៀនពត៌មានសាធារណៈត្រូវសរសេរ ឬ បិទប្រកាសជូនដំណឹងជាផ្លូវការ និង ពត៌មានដទៃទៀតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការសរសេរ ឬ ការបិទប្រកាសពត៌មានជាសាធារណៈ ត្រូវរក្សាទុកអោយបានរយៈ យ៉ាងតិច១០ថ្ងៃ ។

**មាត្រា ១១.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ជាតំណាង និង ជាអ្នកបំរើអោយផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សាត្រូវលើកស្ទួយ និង សំរបសំរួលក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយត្រូវរកប្រភពជំនួយកសាងសំណង់ និង គ្រឿងគរសមត្ថភាព និង ធនធានពី ÷

- ក្នុងឃុំ សង្កាត់របស់ខ្លួនផ្ទាល់

- រាជរដ្ឋាភិបាល និង ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល

- អង្គការជាតិ អន្តរជាតិ និង អង្គការនានានៅមូលដ្ឋាន
- ផ្នែកឯកជន និង សម្បុរសជននានា ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសវិធីសាស្ត្រសមស្រប និង មានប្រសិទ្ធភាព សំរាប់អនុវត្តន៍ក្នុងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសំរបសំរួល និង លើកស្ទួយយ៉ាងសកម្មនូវការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ ក្នុងឃុំ សង្កាត់ ដោយត្រូវបង្កើតឡើងនូវយន្តការដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល និង សហគមន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

កិច្ចពិភាក្សា និង ការអនុវត្តកិច្ចការរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានលក្ខណៈចំហរ និង មានតម្លាភាព។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាអោយឃុំ សង្កាត់នីមួយៗមានធនធានមនុស្ស និង ធនធានសំភារៈសមស្របដើម្បីដំណើរការការងាររបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាអោយសមាជិករបស់ខ្លួន និង មន្ត្រីដែលបានតែងតាំងនៅក្នុងឃុំ សង្កាត់ឱ្យមានការយល់ដឹង និង មានឥរិយាបថសមស្រប ដើម្បីអនុវត្តតួនាទី និង ភារកិច្ចរបស់ខ្លួនតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និង លិខិតបទដ្ឋាន នានាជាធរមាន ។

**មាត្រា ១៤.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការពិនិត្យ និង វាយតំលៃអំពីសកម្មភាពនានាក្នុងការកសាងសមត្ថភាពសាធារណជននៅក្នុងឃុំ សង្កាត់ តាមរយៈ ÷

- ការបណ្តុះបណ្តាល
- ឯកសារ អត្ថបទ ទស្សនាវដ្តី និង សៀវភៅពតិមានផ្សេងៗ
- ការអប់រំតាមរយៈ វិទ្យុ ទូរទស្សន៍ កាសែត និង ប្រព័ន្ធផ្សព្វផ្សាយដទៃទៀត..... ។

**មាត្រា ១៥.-**

ឃុំ សង្កាត់នីមួយៗត្រូវធ្វើសហការជាមួយឃុំ សង្កាត់ផ្សេងទៀតដើម្បីជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក ។

តាមការស្នើសុំរបស់ឃុំ សង្កាត់ផ្សេងទៀត ឃុំ សង្កាត់សាមីអាចផ្តល់យោបល់ និង ផ្តល់សេវាគាំទ្រខាងរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុដល់ឃុំ សង្កាត់នោះ ។

**មាត្រា ១៦.-**

ក្នុងកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់មួយ ជាមួយឃុំ សង្កាត់ដទៃទៀត ត្រូវអនុវត្តទៅតាមកិច្ចព្រមព្រៀង ឬ តាមការចាត់ចែងរួម ដែលនឹងជួយសំរបសំរួលដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព។

ក្រសួងមហាផ្ទៃត្រូវជួយដល់ឃុំ សង្កាត់ដើម្បីរៀបចំកិច្ចព្រមព្រៀង ឬ ការចាត់ចែងការងាររួមគ្នានេះ ។

## ជំពូកទី២

## មេឃុំ ចៅសង្កាត់ គណៈកម្មាធិការនានា និង អ្នកជំនួយការ

**មាត្រា ១៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិតែងតាំងគណៈកម្មាធិការជំនួយការនានា តាមការចាំបាច់ដើម្បីផ្តល់យោបល់ឱ្យខ្លួន ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់តួនាទី ភារកិច្ច បទបញ្ជាផ្ទៃក្នុង និង នីតិវិធីធ្វើការងាររបស់គណៈកម្មាធិការទាំងនេះដោយអនុលោមទៅតាមស្មារតីនៃសេចក្តីណែនាំ និង លិខិតបទដ្ឋាននានារបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ម្នាក់ជានារីដើម្បីអោយទទួលបន្ទុកកិច្ចការនារី និង កុមារ ។

ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែងតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារ ។

ជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារត្រូវបានផ្តល់សិទ្ធិអោយចូលរួមក្នុងរាល់កិច្ចពិភាក្សា ឬ កិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់ឃុំ សង្កាត់ និង កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

**មាត្រា ២០.-**

មេឃុំ ចៅសង្កាត់ត្រូវ ÷

- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង គណៈកម្មាធិការជំនួយការនានារបស់ឃុំ សង្កាត់
- លើកយោបល់ដល់ក្រុមប្រឹក្សាអំពីរបៀបបង្កើន និង កសាងសមត្ថភាពនៃធនធានរបស់ឃុំ សង្កាត់ និង ក្រុមប្រឹក្សាឃុំ សង្កាត់
- លើកយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ពីរបៀបគៀងគរធនធាន និង សមត្ថភាព ដើម្បីអភិវឌ្ឍន៍ឃុំ សង្កាត់

របស់ខ្លួនពីប្រភពនានាមានជាអាទិ៍ ÷

- ភូមិទាំងអស់ក្នុងឃុំ សង្កាត់របស់ខ្លួន
- ឃុំ សង្កាត់ផ្សេងៗ
- រាជរដ្ឋាភិបាល និង ក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល
- ជំនួយឥតសំណងពីអង្គការជាតិ អន្តរជាតិ និង អង្គការនានានៅមូលដ្ឋាន
- ផ្នែកឯកជន និង សម្បុរសជននានា

- ស្វែងរកការចូលរួមក្នុងភាពជាដៃគូពីក្រុមប្រឹក្សាឃុំ សង្កាត់ដែលនៅក្បែរគ្នា
- លើកយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ពីរបៀប ÷
  - រៀបចំ និង អនុម័ត ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
  - អនុវត្ត ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
  - ត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍ ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
  - រៀបចំ និង អនុម័តរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

- របាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ នៅរៀងរាល់ខែអំពីសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ខែកន្លងមក ព្រមទាំងការអនុវត្តន៍គោលនយោបាយ និង ការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

- ធានាអនុវត្តយ៉ាងត្រឹមត្រូវនូវរាល់សេចក្តីសំរេច និង ដីការបស់ឃុំ សង្កាត់
- ធានាគ្រប់គ្រង និង ត្រួតពិនិត្យយ៉ាងត្រឹមត្រូវកិច្ចការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តកិច្ចការប្រចាំថ្ងៃក្នុងឃុំ សង្កាត់
- ពិនិត្យមើលការងាររបស់ស្មៀនឃុំ សង្កាត់ ។

**មាត្រា ២១.-**

ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ត្រូវជួយមេឃុំចៅសង្កាត់ លើបញ្ហាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំទប់ទី២ ឬ ចៅសង្កាត់រងទី២ ត្រូវជួយមេឃុំចៅសង្កាត់ លើបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចការសង្គមកិច្ច រដ្ឋបាល សេវាសាធារណៈ និង សណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់ អាចប្រគល់កិច្ចការបន្ថែមទៀតដល់ជំទប់ ឬ ចៅសង្កាត់រង របស់ខ្លួនតាមការចាំបាច់ ។

ក្នុងករណីមេឃុំ ឬ ចៅសង្កាត់អវត្តមានត្រូវធ្វើការផ្ទេរសិទ្ធិជាលាយលក្ខ័អក្សរទៅជំទប់ ឬ ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងរយៈពេលដែលមេឃុំ ចៅសង្កាត់នោះអវត្តមាន ។

ជំទប់ ឬ ចៅសង្កាត់រងមិនអាចចុះហត្ថលេខាលើឯកសារ លិខិតស្នាមនានា ដោយមិនមានការប្រគល់សិទ្ធិអំណាចពីមេឃុំ ចៅសង្កាត់ ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ ។

**មាត្រា ២២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសមេភូមិម្នាក់ នៅក្នុងភូមិនីមួយៗ ។

មេភូមិ ត្រូវតែងតាំង អនុប្រធានភូមិ និង សមាជិកភូមិ ដើម្បីធ្វើជាជំនួយការ ។

ប្រធានភូមិ អនុប្រធានភូមិ និង សមាជិកភូមិត្រូវតែជាប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៃភូមិនោះហើយត្រូវមាននារីយ៉ាងតិចមួយរូប ។

យោងតាមសភាពការណ៍ជាក់ស្តែងនៃភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំជ្រើសរើសនារីអោយទទួលតំណែងជាមេភូមិ ឬ អនុប្រធានភូមិ ។

បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការតែងតាំងអនុប្រធានភូមិ សមាជិកភូមិ ការផ្លាស់ប្តូរមេភូមិ និងជំនួយការ មេភូមិត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការអនុម័តយល់ព្រមពីគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា ២៣.-**

មេភូមិជាតំណាងអោយប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និង ជាខ្សែរយៈចំបងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ។

មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ ជាតំណាងភូមិក្នុងការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការផ្តល់យោបល់អំពីកិច្ចការភូមិ ។

ក្នុងការសំរេចបញ្ហាណាមួយដែលពាក់ព័ន្ធនឹងភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិគ្រោះយោបល់ជាមួយមេភូមិជាមុនសិន ។

**មាត្រា ២៤.-**

មេភូមិត្រូវ ÷

- បង្កើនការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន
- ចូលរួមកិច្ចប្រជុំក្នុងគណកម្មាធិការនានារបស់ឃុំ សង្កាត់ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ពន្ធ័ក្នុងភូមិរបស់ខ្លួននៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តំរូវ
- ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីតំរូវការ និង ផលប្រយោជន៍របស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និង កសាងសមត្ថភាពនៃធនធានរបស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការផែនការអភិវឌ្ឍន៍ និង ថវិកាអំពី ÷

- **តំរូវការ និង អាទិភាពរបស់ភូមិដើម្បីបញ្ចូលក្នុងថវិកា និង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**
- **អនុវត្តថវិកា និង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន**
- **ត្រួតពិនិត្យ និង វាយតំលៃ ការអនុវត្តថវិកា និង ផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន**

- ធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិ ដើម្បីបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់អោយដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ពិគ្រោះយ៉ាងទៀងទាត់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន
- ដោះស្រាយបញ្ហាដែលជាផលប្រយោជន៍រួមជាមួយភូមិក្បែរគ្នា
- ចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៥.-**

មេភូមិ មិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬ ការផ្ទេរអំណាច ឬ ការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ ។

មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិត្រូវជួបប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ ។

**មាត្រា ២៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិភាក្សាជាមួយមេភូមិ ដើម្បីរៀបចំអោយមានទីកន្លែងសំរាប់មេភូមិជួបប្រាស្រ័យជាមួយមជ្ឈដ្ឋាននានាតាមភូមិនីមួយៗ ។

ទីកន្លែងនោះមានជាទីស្នាក់ការភូមិចំពោះកន្លែងដែលមានទីស្នាក់ការភូមិ ។ ចំពោះកន្លែងដែលគ្មានស្នាក់ការភូមិត្រូវពិគ្រោះពិភាក្សាគ្នាដើម្បីរកទីកន្លែងសមស្របណាមួយដែលអាចជាសាលារៀន វត្តអារាម វិហារសាសនា អាគារសាធារណៈ ឬ គេហដ្ឋានផ្ទាល់របស់មេភូមិ ។ ការជ្រើសរើសយកកន្លែងទាំងនេះត្រូវមានការពិគ្រោះពិភាក្សាអោយឯកភាពគ្នាពីក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ នឹងត្រូវមានការយល់ព្រមជាមុនពីម្ចាស់ទីកន្លែងទាំងនោះ ។ មេភូមិ និង ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្សព្វផ្សាយទីកន្លែងនោះដល់សាធារណៈជន ។

ទីកន្លែងនេះត្រូវបើកទទួលប្រជាពលរដ្ឋយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍ ។

មេភូមិ ឬ អនុប្រធានភូមិ ឬ សមាជិកភូមិត្រូវមានវត្តមាននៅទីកន្លែងដែលបានកំណត់នោះនាថ្ងៃនោះ ដើម្បីជួបប្រជាពលរដ្ឋ ។

ក្រៅពីការជួបប្រាស្រ័យជាទៀងទាត់ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅទីកន្លែងដែលបានកំណត់នេះ មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិអាចនឹងជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនជាប្រចាំតាមការចាំបាច់ ។

**មាត្រា ២៧.-**

មេភូមិត្រូវធានាផ្តល់ព័តមានឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារព័តមានទាំងនោះអាចរួមមាន ពតិមានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់ ។

**មាត្រា ២៨.-**

មេភូមិពុំមានសិទ្ធិអំណាចសំរេចបញ្ហាណាមួយ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃដែលបានអនុមត័យល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់បានឡើយ ។

**មាត្រា ២៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬ គណៈកម្មាធិការ ឬ អង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

## ជំពូកទី៣

## សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់

**មាត្រា ៣០.-**

ប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្តាប់រាល់កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បាន ប៉ុន្តែពុំមានសិទ្ធិអនុម័តបានទេ ។

ប្រជាពលរដ្ឋអាចលើកសំណួរដល់មេឃុំ ចៅសង្កាត់ ឬ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោម ទៅតាមបទបញ្ជាផ្ទៃក្នុងសំរាប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣១.-**

ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើ ឬ ធ្វើការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬ ការប្តឹងតវ៉ានោះជាក់ហិត ។

ចំពោះសំណើ ឬ ការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់អាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដោះស្រាយ ហើយចាត់អោយជូនពតិមានអំពីការដោះស្រាយនោះដល់ប្រជាពលរដ្ឋវិញ រួចហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចប្រជុំបន្ទាប់ ។

ចំពោះសំណើ ឬ ការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់មិនអាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដាក់ក្នុងរបៀបវារៈអង្គប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

មេឃុំ ចៅសង្កាត់ ត្រូវជូនពត៌មានដល់ប្រជាពលរដ្ឋអំពីការដោះស្រាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣២.-**

ចំពោះសំណើ ឬ ការប្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍ជូនក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលមានសមត្ថកិច្ច ។

**មាត្រា ៣៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាផ្សព្វផ្សាយពត៌មានអោយបានទៀងទាត់ដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ អំពីបញ្ហាទាំងឡាយស្របតាមសមត្ថកិច្ចរបស់ខ្លួន និង អំពីសេចក្តីសំរេចនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ជំពូកទី៤
## វិធានការវិន័យ និង ការបញ្ឈប់មុខតំណែងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៣៤.-**

រាល់ការចាត់វិធានការដាក់វិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ ដូចមានចែងក្នុងមាត្រា ៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមការបោះឆ្នោតយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

**មាត្រា ៣៥.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្តល់ពត៌មានដល់ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការបញ្ឈប់ពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៦ និង មាត្រា ៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៦.-**

ក្រោយពិនិត្យឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តត្រឹមត្រូវតាមសមត្ថកិច្ចរបស់ខ្លួនហើយ ក្រសួងមហាផ្ទៃត្រូវស្នើសុំទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការបញ្ឈប់ពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្នើអោយជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីមកជំនួសស្របតាមបែបបទ នីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

មាត្រា ៣៧.-

បន្ទាប់ពីទទួលបានលិខិតសំណូមពររបស់ក្រសួងមហាផ្ទៃហើយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសបេក្ខជនថ្មីដាក់ជំនួសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបញ្ឈប់ពីតំណែង ស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

មាត្រា ៣៨.-

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយ ដោយអនុលោមទៅតាមមាត្រា ៥៧ ឬ មាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់មានរយៈពេលមិនលើសពី ១៨០ថ្ងៃ គិតចាប់ពីថ្ងៃរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់អោយមានការគ្រប់គ្រងឃុំ សង្កាត់នោះស្របតាមមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

មាត្រា ៣៩.-

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយ ដោយអនុលោមទៅតាមមាត្រា ៥៧ ឬ មាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអណត្តិដែលនៅសល់មានរយៈពេលលើសពី ១៨០ថ្ងៃ ក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ស្នើសុំអោយរៀបចំបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីមកជំនួស ។

ការបោះឆ្នោតឡើងវិញ ត្រូវរៀបចំឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

មាត្រា ៤០.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវកំណត់កាលបរិច្ឆេទសំរាប់ការបោះឆ្នោតឡើងវិញក្នុងរយៈពេលយ៉ាងយូរ ៧ ថ្ងៃ បន្ទាប់ពីមានសំណើដែលតំរូវអោយមានការបោះឆ្នោតឡើងវិញ ។

មាត្រា ៤១.-

បន្ទាប់ពីបានទទួលបានលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃអំពីកាលបរិច្ឆេទសំរាប់ការបោះឆ្នោតឡើងវិញ គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតឡើងវិញដោយអនុលោមទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

## ជំពូកទី៥

## ទំនាក់ទំនងរវាងឃុំ សង្កាត់ជាមួយរាជរដ្ឋាភិបាល

## ក្រសួង ស្ថាប័ន អាជ្ញាធរ និង ភ្នាក់ងាររបស់រដ្ឋ

**មាត្រា ៤២.-**

រាល់ទំនាក់ទំនងជាផ្លូវការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរ ភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និង អន្តរជាតិនានា ត្រូវប្រព្រឹត្តទៅតាមរយៈក្រសួងមហាផ្ទៃ ។

**មាត្រា ៤៣.-**

ក្រសួងមហាផ្ទៃអាចធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ឱ្យជួយក្នុងកិច្ចការទំនាក់ទំនងនេះ និង សំរបសំរួលការអនុវត្តតួនាទី មុខងារ អំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយ វិមជ្ឈការ និង អនុក្រឹត្យពាក់ពន្ធ័នានា ស្របទៅតាម សភាពការណ៍ជាក់ស្ដែង ។

ការធ្វើប្រតិភូកម្មអំណាចនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤៤.-**

ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់ពីរ ឬ ច្រើន និងធានាដោះស្រាយរាល់ទំនាស់ និង ជំលោះដែលក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន។

**មាត្រា ៤៥.-**

ក្រសួងមហាផ្ទៃត្រូវសហ និង ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អង្គការអន្តរជាតិនានាដើម្បីដោះស្រាយទំនាស់ ឬ ជំលោះដែលកើតមានឡើងរវាងក្រសួង ស្ថាបន័ ឬ អង្គការទាំងនោះជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ ។

**មាត្រា ៤៦.-**

ក្រសួងមហាផ្ទៃត្រូវធានាថាការសំរុះសំរួល ការដោះស្រាយទំនាស់ និង ជំលោះរវាងឃុំ សង្កាត់ និង ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អន្តរជាតិ មានភាពយុត្តិធម៌ ត្រឹមត្រូវ រក្សាបាននូវផលប្រយោជន៍ទាំងសងខាង និង អនុវត្តបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

**មាត្រា ៤៧.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលអាចត្រួតពិនិត្យលើសេចក្ដីសំរេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ

ធ្វើអន្តរាគមន៍លើសេចក្តីសំរេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅពេលដែលការត្រួតពិនិត្យ ឬ ការធ្វើអន្តរាគមន៍ទាំងនោះត្រូវបានអនុញ្ញាតដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬ លិខិតបទដ្ឋានដទៃទៀត ដែលបានពិនិត្យ ឬ បានសម្រេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤៨.–**

ក្រសួងមហាផ្ទៃអាចត្រួតពិនិត្យ ឬ ធ្វើអន្តរាគមន៍ផងដែរ ក្នុងករណីដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អង្គការជាតិ និង អង្គការអន្តរជាតិនានាបានធ្វើសេចក្តីរាយការណ៍ ឬ ប្តឹងតវ៉ាចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៤៩.–**

ក្រសួង ឬ ស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាបង្កលក្ខណៈសម្បត្តិឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តមុខងារ និង អំណាចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានត្រឹមត្រូវតាមនីតិវិធី ដែលបានតម្រូវដោយ ÷

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- រាជក្រឹត្យ
- អនុក្រឹត្យ ប្រកាស ឬ លិខិតបទដ្ឋាននានាដែលបានពិនិត្យ ឬ បានសម្រេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បទបញ្ជាផ្ទៃក្នុង ដីកា ឬ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥០ –**

ក្នុងករណីដែលក្រសួង ស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តមុខងារ និង អំណាចមិនត្រឹមត្រូវតាមនីតិវិធី និង តំរូវការផ្នែកច្បាប់ ក្រសួង ស្ថាប័នទាំងនោះត្រូវ ÷

- ផ្តល់ដំណឹងជាលាយល័ក្ខអក្សរដល់ក្រសួងមហាផ្ទៃ អំពីនីតិវិធី និង តំរូវការផ្នែកច្បាប់ ដែលតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្ត
- ធ្វើសំណើជាលាយល័ក្ខអក្សរទៅក្រសួងមហាផ្ទៃនូវកំហុសឆ្គងដែលតម្រូវឱ្យកែប្រែ និង ពេលវេលាដែលត្រូវកែប្រែ និង ផ្តល់ពត៌មានអំពីលទ្ធផលបញ្ចប់នៃការកែប្រែនោះ ។

**មាត្រា ៥១.–**

ក្រសួងមហាផ្ទៃត្រូវកំណត់ លក្ខណៈវិនិច្ឆ័យនៃការត្រួតពិនិត្យ និង ការធ្វើអន្តរាគមន៍ដូចតទៅ ÷

- ហេតុផលនៃកំហុសឆ្គង

- ប្រភេទនៃវិធានការ ឬ សកម្មភាពអន្តរាគមន៍ដែលនឹងត្រូវធ្វើ

- ការគាំទ្រ និង ការបង្កើនសមត្ថភាពណាមួយដែលត្រូវផ្តល់ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងការគ្រប់គ្រង ការអនុវត្តន៍មុខងារ និង សិទ្ធិអំណាចឱ្យបានត្រឹមត្រូវ និងកាន់តែប្រសើរឡើង ។

**មាត្រា ៥២.-**

ក្នុងការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រសួងមហាផ្ទៃត្រូវ ÷

- ផ្តល់យោបល់ជាលាយល័ក្ខអក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីនីតិវិធី និង តំរូវការផ្នែកច្បាប់ទាំងឡាយដែលត្រូវអនុវត្ត

- ណែនាំជាលាយល័ក្ខអក្សរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតំរូវកំហុសឆ្គងក្នុងកំឡុងពេលមួយសមស្រប និង ត្រូវរាយការណ៍នូវលទ្ធផលនៃការកែតម្រូវនោះមកក្រសួងមហាផ្ទៃវិញ ។

**មាត្រា ៥៣.-**

ពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់គ្មានសមត្ថភាព ឬ គ្មានបំណងដើម្បីកែតំរូវកំហុសឆ្គង ក្រសួងមហាផ្ទៃត្រូវធ្វើកិច្ចការនោះជំនួសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តសេចក្តីសម្រេច និង កិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយក៏ត្រូវចាត់វិធានការចាំបាច់ផងដែរដើម្បីអភិវឌ្ឍន៍នូវសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥៤.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល មិនអាចធ្វើសេចក្តីសម្រេចក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់បានទេ លើកលែងតែនៅក្នុងករណីដែលបានអនុញ្ញាតដោយច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស ឬ លិខិតបទដ្ឋាននានាដែលបានពិនិត្យ និង បានសម្រេចយល់ព្រម ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

សេចក្តីសំរេចដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលបានធ្វើឡើងក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែធានាថាក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តតាមនីតិវិធី និងតំរូវការផ្នែកច្បាប់ដែលបានចែងក្នុងករណីពិសេសនោះ ។

## ជំពូកទី៦

## មុខងារ និង អំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

## និង ការផ្ទេរអំណាចរបស់រដ្ឋទៅអោយឃុំ សង្កាត់

**មាត្រា ៥៥.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ ធ្វើកិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែស្នើសុំអនុញ្ញាតជាមុនពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៥៦.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ ធ្វើកិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្ទេរធនធាន និង សមត្ថភាព ជាចាំបាច់ដើម្បីធានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តបាននូវអំណាច ឬ ការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងដែលបានធ្វើប្រតិភូកម្មនោះ ។

ក្រសួងមហាផ្ទៃត្រូវកំណត់នីតិវិធីជាក់ស្តែងថែមទៀតដើម្បីអនុវត្តនូវបទប្បញ្ញត្តិនេះ ។

**មាត្រា ៥៧.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវរាយការណ៍អំពីការធ្វើប្រតិភូកម្មអំណាច ឬ ការផ្ទេរការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងទាំងអស់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ជូនក្រសួងមហាផ្ទៃ និង អាជ្ញាធរខេត្ត ក្រុង ដែលពាក់ព័ន្ធ ។

**មាត្រា ៥៨.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចចុះកិច្ចព្រមព្រៀង ឬ ការចាត់ចែងការងារណាមួយជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អន្តរជាតិ ឬ ផ្នែកឯកជនណាមួយ ដោយគ្មានការយល់ព្រមពីក្រសួងមហាផ្ទៃបានឡើយ ។

**មាត្រា ៥៩.-**

ក្រសួងមហាផ្ទៃត្រូវដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ពិភាក្សា និង អនុម័ត នូវកិច្ចព្រមព្រៀង ឬ ការចាត់ចែងណាមួយដែលបានស្នើឡើងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ តែកិច្ចព្រមព្រៀង ឬ ការចាត់ចែងនោះមិនមានចែងក្នុងប្រកាស ឬ គោលការណ៍ណែនាំដែលបានសម្រេចដោយគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦០.-**

ក្រសួងមហាផ្ទៃត្រូវត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀង និង ត្រូវធានាថាធនធាន សមត្ថភាព និង កំរៃដែលបានយល់ព្រមផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានប្រគល់ជូនយ៉ាងត្រឹមត្រូវ ។

**មាត្រា ៦១.-**

ឃុំ សង្កាត់មានតួនាទី និង មុខងារយ៉ាងទូលំទូលាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលក្នុងនោះមានមុខងារ និង តួនាទីជាមូលដ្ឋានគឺ ÷

- រក្សាសន្តិសុខ និង សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
- ចាត់ចែងសេវាកម្មសាធារណៈចាំបាច់ និង មើលការខុសត្រូវឱ្យកិច្ចការនោះដំណើរការបានល្អ
- លើកទឹកចិត្តអោយមានការបង្កើនជាសុខភាព និង សុខមាលភាពប្រជាពលរដ្ឋ
- ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច ហើយលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយមានលក្ខណៈ

ល្អប្រសើរឡើងជាលំដាប់

- ការពារ និង ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ

- ផ្សះផ្សាការខ្វែងមតិយោបល់គ្នា ហើយជំរុញអោយមានការយោគយល់ និង ការអត់ឱនទៅវិញទៅមករវាងប្រជាពលរដ្ឋ

- ទទួលភារៈបំពេញរងលើកិច្ចការទូទៅបន្ថែមទៀត ដើម្បីបំពេញទៅតាមតំរូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៦២.-**

ឃុំ សង្កាត់ត្រូវអនុវត្តមុខងារមួយផ្នែក ឬ ទាំងអស់នៃមុខងារ និង ការទទួលខុសត្រូវដែលបានធ្វើប្រតិភូកម្មឱ្យបានសមស្របទៅនឹងធនធានដែលបានផ្តល់ ដើម្បីលើកស្ទួយ និង គាំទ្រដល់ការអនុវត្តន៍តួនាទី និង មុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រកបដោយចីរភាព និង បំពេញបានទៅតាមតំរូវការជាមូលដ្ឋាន។

**មាត្រា ៦៣.-**

ឃុំ សង្កាត់មានសិទ្ធិជ្រើសរើស និង អនុវត្តសកម្មភាពណាមួយ ដែលស្ថិតនៅក្នុងសមត្ថកិច្ចនៃមុខងារជាទូទៅ និង ដែលស្ថិតនៅក្នុងក៏រិតនៃធនធានដែលមាន។

**មាត្រា ៦៤.-**

កិច្ចការជាក់លាក់មួយចំនួនត្រូវបានហាមឃាត់ មិនឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្ត រួមមាន ÷

- វិស័យព្រៃឈើ
- វិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍
- វិស័យការពារជាតិ
- វិស័យសន្តិសុខជាតិ
- វិស័យរូបិយវត្ថុ
- វិស័យនយោបាយក្រៅប្រទេស
- វិស័យគោលនយោបាយសារពើពន្ធ
- វិសយ័ផ្សេងទៀតដែលកំណត់ដោយក្រសួងមហាផ្ទៃ បន្ទាប់ពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ។

**មាត្រា ៦៥.-**

ឃុំ សង្កាត់អាចមានសិទ្ធិអំណាចដើម្បីជ្រើសរើស និង អនុវត្តសកម្មភាពដែលស្ថិតក្នុងតួនាទី និង មុខងារដែលនៅក្រៅយុត្តាធិការរបស់ខ្លួន ក្នុងករណីមានការអនុញ្ញាតពិសេសណាមួយពីក្រសួង ស្ថាប័ននានារបស់រដ្ឋ ផ្អែកតាមការសំរបសំរួលដោយក្រសួងមហាផ្ទៃ និង ត្រូវរាយការណ៍ជូនដល់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦៦.-**

ឃុំ សង្កាត់ត្រូវចាត់ចែងនិងប្រើប្រាស់ធនធានដែលមាន ដើម្បីជ្រើសរើសនិងអនុវត្តសកម្មភាពរបស់ខ្លួន។

**មាត្រា ៦៧.-**

មុខងារ និង តួនាទីចំបងរបស់ឃុំ សង្កាត់គឺត្រូវសម្របសម្រួល និង ជំរុញឱ្យមានការអភិវឌ្ឍន៍ក្នុងឃុំ សង្កាត់របស់ខ្លួន ដោយត្រូវជ្រើសរើសវិធីសាស្ត្រសមស្រប និង មានប្រសិទ្ធិភាព ដើម្បីអនុវត្ត និង ផ្តល់សេវាកម្មអោយស្របតាមជំរើសដែលបានសំណូមពរដោយស្ថាប័នខាងលើ ។

**មាត្រា ៦៨.-**

ប្រសិនបើមុខងារ ឬ សេវាដែលឃុំ សង្កាត់ទទួលបានសិទ្ធិអំណាចដើម្បីអនុវត្ត កំពុងត្រូវបានផ្តល់អោយដោយភ្នាក់ងារ ឬ អង្គការដទៃទៀត ដោយមិនគិតក្នុងបន្ទុកចំណាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់គួរទទួលស្គាល់កិច្ចការទាំងនេះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីធ្វើការអភិវឌ្ឍន៍នៅកន្លែងដែលមិនទាន់មានអ្នកជួយគាំទ្រ ។

**មាត្រា ៦៩.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវសិក្សា និង កំណត់ឱ្យបានជាក់លាក់ថែមទៀតអំពីការបែងចែកមុខងាររវាងរដ្ឋបាលថ្នាក់កណ្តាល និង ឃុំ សង្កាត់ ។

ការបែងចែកខាងលើត្រូវមានគោលដៅដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្តន៍។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវធ្វើការបែងចែករវាងសេវាកម្មដែលត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់កណ្តាល ភ្នាក់ងារនានារបស់រដ្ឋ អង្គការជាតិ អន្តរជាតិ និង វិស័យឯកជន ជាមួយសេវាកម្មដែលត្រូវផ្តល់ដោយឃុំ សង្កាត់ ។

**មាត្រា ៧០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការរៀបចំ ការអនុមត័ និង ការអនុវត្តន៏ផែនការអភិវឌ្ឍន៍ និង ផែនការថវិកាឃុំ សង្កាត់របស់ខ្លួន ។

ការរៀបចំ ការអនុមត័ និង ការអនុវត្តន៏ផែនការអភិវឌ្ឍន៏ឃុំ សង្កាត់ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ និង ប្រើប្រាស់ថវិកាដោយអនុលោមទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៧២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យឡើងវិញរាល់សកម្មភាពនៃការចាត់ចែង និង កិច្ចព្រមព្រៀងទាំងឡាយដែលបានរៀបចំឡើងក្នុងនាមឃុំ សង្កាត់ ឬ ដោយឃុំ សង្កាត់ផ្ទាល់ ឬ ភូមិមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទីមួយនេះ ។

ការចាត់ចែង ឬ កិច្ចព្រមព្រៀងទាំងនោះរួមមានការផ្ទេរអំណាច ឬ សិទ្ធិពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ ការធ្វើសហប្រតិបត្តិការ ឬ ការជួយគាំទ្រពីកម្មវិធី និង អង្គការនានា ។

ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើការពិភាក្សាជាមួយគ្រប់ក្រសួង ស្ថាប័ន តំណាងកម្មវិធី និង អង្គការដែលពាក់ពន្ធ័ដើម្បី ៖

- បញ្ជាក់ថាកិច្ចព្រមព្រៀង ឬ ការចាត់ចែងដែលកំពុងអនុវត្ត ពិតជាបានអនុវត្តនៅក្នុងឃុំ សង្កាត់ ឬភូមិ របស់ខ្លួន
- ពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀង ឬ ការចាត់ចែងណា ដែលផ្ទុយនឹងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ឬ ផ្ទុយពីគោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីស្នើសុំធ្វើការកែសម្រួលអោយបានសមស្រប ។

**មាត្រា ៧៣.-**

ក្នុងអាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ដើម្បីកំណត់ និង បែងចែកភារកិច្ចជាក់លាក់រវាងរដ្ឋបាលថ្នាក់កណ្ដាល ថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

**មាត្រា ៧៤.-**

គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវពិនិត្យបញ្ជាក់ថា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមានភាពសមស្រប ឬ មិនសមស្របទៅនឹងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

ច្បាប់ ព្រះរាជក្រឹ្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមិនសមស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវរៀបចំបែបបទ និង នីតិវិធីធ្វើវិសោធនកម្ម ឬ កែសំរួលអោយបានសមស្រប ។

**មាត្រា ៧៥.-**

គ្រប់ក្រសួង និង ស្ថាប័ននានារបស់រដ្ឋាភិបាលត្រូវ ៖

– បញ្ជាក់ថាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិត បទដ្ឋាន ទាំងអស់ដែលពាក់ពន្ធ័នឹងក្រសួង និង ស្ថាប័នរបស់ខ្លួនកំពុង អនុវត្តនៅតាមឃុំ សង្កាត់ និង ភូមិ ត្រូវតែសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

– ពិនិត្យឡើង វិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានដែលផ្ទុយនឹងគោលការណ៍វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ពិនិត្យ និង ស្នើសុំធ្វើ វិសោធនកម្មជាបន្ទាន់ ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា ៧៦.–**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧៧.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តអនុក្រឹត្យនេះឱ្យ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង ឃូ ហុកគ្រី

# ឧបសម្ព័ន្ធទី៣៖ កម្រងរូបភាព និស្សិត និង សាស្ត្រាចារ្យណែនាំ





